# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម

សំណុំរឿង០០២ ▪ របាយការណ៍លេខ ៤៥ ▪ សវនាការលើកស្តុតាង ▪ សប្តាហ៍ទី ៤០ ▪ ថ្ងៃទី០៤ - ០៧ ខែធ្នូ ឆ្នាំ២០១២



ករណីរបស់ជនជាប់ចោទ លោក **នួន ជា** លោក **ខៀវ សំផន** និង លោក **អៀង សារី**

Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*អ៊ីចឹងហើយ បានជារាល់ពេលដែលខ្ញុំនៅតែនឹកឃើញពីអ្វីដែលបានកើតឡើងពីមុន*
*ហើយធ្វើឲ្យខ្ញុំខឹង...ខឹងខ្លាំងណាស់ វាហាក់ដូចជានៅថ្មីៗនឹងភ្នែកខ្ញុំអ៊ីចឹង។[1]*

- ***ដើមបណ្តឹងរដ្ឋប្បវេណី គីម វណ្ណី***

## ផ្នែកទី ១៖ ទិដ្ឋភាពទូទៅ

នាសប្តាហ៍នេះ អង្គជំនុំជម្រះ បានស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប និងសាក្សីមួយរូប។ ដើមបណ្តឹងរដ្ឋប្បវេណី **ទឹង សុខា** ដើមបណ្តឹងរដ្ឋប្បវេណី **ពេជ ស្រីផល** និងដើមបណ្តឹងរដ្ឋប្បវេណី **គីម វណ្ណី** បានមានវត្តមាននៅក្នុងទីក្រុងភ្នំពេញ នៅពេលដែលខ្មែរក្រហមវាយដណ្តើមយកបានទីក្រុងទាំងស្រុង។ ដូច្នេះហើយ ពួកគាត់ទាំងបី បានមកផ្តល់សក្ខីកម្មស្តីពីស្ថានភាពមុនក្នុងទីក្រុង ស្ថានភាពក្នុងអំឡុងពេលវាយប្រហារ និងស្ថានភាពក្រោយការយកជ័យជម្នះបានទីក្រុងភ្លាមៗរបស់កងទ័ពខ្មែរក្រហម។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូប ត្រូវបានជម្លៀសចេញពីទីក្រុង ហើយពួកគាត់បានរ៉ាយរ៉ាប់យ៉ាងពិស្តារនូវទុក្ខសោកវេទនាដែលបានទទួលក្នុងដំណាក់កាលនោះ។ ដោយឡែកសាក្សី **ហ៊ុន ឈុនលី** ជាអ្នកដែលធ្លាប់បានរស់នៅខេត្តបាត់ដំបង ក្នុងថ្ងៃដណ្តើមបានជ័យជម្នះរបស់ខ្មែរក្រហម។ គាត់បានរៀបរាប់ពីការសង្កេតខ្លះៗរបស់គាត់ ស្តីពីការបញ្ជូនប្រជាជនទៅក្នុងខេត្តដែលគាត់រស់នៅ។ សាក្សីរូបនេះដែលជាវេជ្ជបណ្ឌិតមួយរូប បានផ្តល់នូវសក្ខីកម្មយ៉ាងពិស្តារអំពីស្ថានភាពមួយចំនួនដែលបានកើតមាននៅក្នុងមន្ទីរពេទ្យខេត្ត ឬហៅថា ជាមន្ទីរពេទ្យបង្អែក រួមទាំងស្ថានភាពរបស់បុគ្គលិកពេទ្យ និងអ្នកជម្ងឺដែលបានសម្រាកព្យាបាលនៅទីនោះ។

មានបញ្ហាផ្លូវច្បាប់ និងនីតិវិធីសំខាន់ៗ បានកើតមានឡើងផងដែរក្នុងកិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ ជាពិសេស ទាក់ទងនឹងប្រសិទ្ធភាពនៃការចូលរួមតាមដានសវនាការរបស់ជនជាប់ចោទ **អៀង សារី**

របៀបនៃការដាក់សំណួរក្នុងពេលសួរដេញដោលសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី តួនាទីដ៏សមរម្យរបស់មេធាវីប្រឹក្សាក្ដី ហើយនិងបញ្ហានៃការរៀបចំពិនិត្យពិច័យផ្នែកយុត្តាធិការផងដែរ។

## ផ្នែកទី ២៖ សក្ខីកម្មសង្ខេបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី

ដើមបណ្ដឹងរដ្ឋប្បវេណីទាំងបីរូប បានមកផ្ដល់សក្ខីកម្មនាសប្ដាហ៍នេះ ស្ដីពីស្ថានភាពរស់នៅក្នុងទីក្រុងភ្នំពេញ ភ្លាមៗមុន និងក្នុងអំឡុងពេលនៃការដួលរលំទីក្រុង។ ពួកគាត់ក៏បានផ្ដល់សក្ខីកម្មផងដែរ ស្ដីពីស្ថានភាពដែលពួកគាត់ និងក្រុមគ្រួសាររបស់គាត់បានប្រឈមមុខក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុង។ សាក្សី **ហ៊ុន ឈុនលី** បានផ្ដល់សក្ខីកម្មសំខាន់ៗស្ដីពីបទពិសោធន៍របស់គាត់ដែជាគ្រូពេទ្យម្នាក់នៅខេត្តបាត់ដំបង ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។

### ក. សក្ខីកម្មរបស់អ្នកស្រី ទឹង សុខា

ដើមបណ្ដឹងរដ្ឋប្បវេណី **ទឹង សុខា** (TCCP 188) ជាគ្រូបង្រៀនមួយរូប ដែលត្រូវបានជម្លៀសចេញពីភ្នំពេញ។ លោកស្រីបានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះស្ទើរតែពេញមួយថ្ងៃអង្គារ ដោយបានផ្ដល់នូវរឿងរ៉ាវយ៉ាងលម្អិត ស្ដីពីការជម្លៀសវគ្គទីមួយ និងវគ្គទីពីរក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

#### *ក.១. ព្រឹត្តិការណ៍មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

យោងតាមដើមបណ្ដឹងរដ្ឋប្បវេណី **ទឹង សុខា** បានឲ្យដឹងថា មុនឆ្នាំ១៩៧៥ ជីវភាពរស់នៅក្នុងទីក្រុងភ្នំពេញ គឺមានសភាពសមរម្យ ដោយប្រជាជនមានម្ហូបអាហារហូប និងមានលុយកាក់ចាយគ្រប់គ្រាន់។ ក៏ប៉ុន្តែស្ថានភាពចាប់ផ្ដើមក្លាយទៅជាច្របូកច្របល់ និងរឹករវ ចាប់តាំងពីនៅមុនថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ។ លោកស្រី **ទឹង សុខា** បានឮសំឡេងវាយប្រហារដោយស្នូរកាំភ្លើង និងការទម្លាក់គ្រាប់បែកយ៉ាងកងរំពង រីឯតម្លៃម្ហូបអាហារ និងអង្ករ ក៏បានចាប់ផ្ដើមឡើងថ្លៃខ្ពស់យ៉ាងគំហុកចាប់ពីពេលនោះមក។ គ្រានោះ ភូមិឋានកំណើតរបស់សាច់ញាតិលោកស្រីនៅឯខេត្តកំពង់ស្ពឺ ត្រូវបានបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែក ហើយការទម្លាក់គ្រាប់នេះបានសម្លាប់សមាជិកគ្រួសាររបស់លោកស្រីចំនួន៤រូប។ ប្រជាជនជាច្រើន មកពីបណ្ដាខេត្តផ្សេងៗទៀត រាប់បញ្ចូលទាំងសាច់ញាតិរបស់លោកស្រីបានមកជ្រកកោនក្នុងទីក្រុងភ្នំពេញ។

#### *ក.២. ការជម្លៀសចេញពីទីក្រុងភ្នំពេញ*

យោងតាមលោកស្រី **ទឹង សុខា** នៅតែមានឮ "ស្នូរគ្រាប់កាំភ្លើង និងការបន្តទម្លាក់គ្រាប់បែក" ក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នាររសៀលថ្ងៃដដែល គាត់បានឃើញទាហានខ្មែរក្រហមប្រាប់ទៅប្រជាជនឲ្យចេញពីភ្នំពេញនៅម៉ោង៥រសៀល។ ខ្មែរក្រហមបានប្រាប់ពួកគេថា មិនចាំបាច់យកអីវ៉ាន់ច្រើនជាប់តាមខ្លួនទេ ពីព្រោះពួកគេនឹងត្រូវត្រឡប់មកវិញក្នុងរយៈពេល៣ថ្ងៃក្រោយ។ ដូច្នេះ លោកស្រី **ទឹង សុខា** បានចាកចេញ

ជាមួយនឹងកូនៗ ប្ដី ឪពុកម្ដាយក្មេក និងប្អូនៗបង្កើតរបស់លោកស្រី ព្រមទាំងសាច់ញាតិមួយចំនួនទៀតផង។ នៅពេលនោះ កូនៗរបស់លោកស្រីម្នាក់មានអាយុ៦ឆ្នាំ និងម្នាក់ទៀតអាយុ៣ឆ្នាំ។ លោកស្រី **ទឹង សុខា** និងក្រុមរបស់គាត់ដែលមានគ្នា១៤នាក់ បាននាំគ្នាដើរតាមមនុស្សម្នាដទៃទៀតតាមបណ្ដោយមហាវិថីព្រះមុនីវង្ស ដោយគាត់បានបញ្ជាក់ថា ទាហានខ្មែរក្រហមដែលប្រដាប់ដោយអាវុធគ្រប់ដៃឈរតាមផ្លូវ មានអាយុមិនច្រើនទេ សុទ្ធតែ "ក្មេងៗ"។

នៅពេលព្រឹកថ្ងៃបន្ទាប់ លោកស្រី **ទឹង សុខា** បានដឹងថា គាត់បានដេកក្បែរសាកសពមនុស្សស្លាប់មួយចំនួននៅ **ក្រោះបាយ**។ លោកស្រី ក៏បានឃើញសាកសពដែលត្រូវបានគេកាត់ក្បាលអណ្ដែតតាមមាត់ទន្លេ ដែលលោកស្រីជឿជាក់ថា ជាសាកសពរបស់អតីតទាហាន **លន់ នល់** ដោយសារតែបានឃើញមានស្លៀកឯកសណ្ឋានទាហានពណ៌គគីរ។ ដោយមិនមានគោលដៅណាមួយពិតប្រាកដ លោកស្រី **ទឹង សុខា** បានបន្តដើរតាមហ្វូងមនុស្សម្នាទាំងឡាយតាមបណ្ដោយផ្លូវជាតិលេខ ២។

អស់រយៈពេល១១ថ្ងៃ និង១១យប់ លោកស្រីបានដើរដល់ភូមិថ្នល់ដាច់ ស្រុកបាទី ខេត្តតាកែវ។ ដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា ខ្លួនបានស្នាក់នៅក្នុងស្រុកបាទីប្រមាណជា៥ខែ។ ក្រោយពេលទៅដល់ខេត្តតាកែវ ខ្មែរក្រហមបានដកហូតយកកូនវិទ្យុរបស់លោកស្រី ដោយបាននិយាយថា វាជាសម្បត្តិទ្រព្យរបស់ "អង្គការ"។ ទោះជាយ៉ាងនេះក្ដី លោកស្រី **ទឹង សុខា** នៅតែអាចរក្សាបាននូវមាសប្រាក់ និងគ្រឿងអលង្ការខ្លះៗទុកសម្រាប់ដោះដូរជាមួយនឹងម្ហូបអាហារ និងវត្ថុប្រើប្រាស់ចាំបាច់ខ្លះៗ ព្រមទាំងសម្រាប់តម្លៃសំបុត្រសាឡាងដើម្បីឆ្លងទន្លេទៅមក។ នៅភូមិថ្នល់ដាច់ ជាទីកន្លែងដែលលោកស្រីបានជួបជុំជាមួយសាច់ញាតិខាងឪពុករបស់លោកស្រី ហើយលោកស្រីក៏ត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយពួកគេនៅទីនោះ។

នៅក្នុងភូមិ គេបានចាត់ទុកប្រជាជនទៅដល់ថ្មីថាជា "ប្រជាជន១៧មេសា" ឬ "ប្រជាជនថ្មី" រីឯអ្នកដែលមានកំណើតកើតនៅទីនោះ ត្រូវបានហៅថាជា "ប្រជាជនមូលដ្ឋាន"។ សហករណ៍មិនទាន់ត្រូវបានបង្កើតនៅឡើយទេ ហើយប្រជាជនត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយគ្នា និងអាចដើរហើរបានដោយសេរី។ ក្រោយមកទៀត ពួកគេត្រូវបានបំបែកពីគ្នា រីឯការដើរហើរត្រូវបានហាមប្រាម។ លោកស្រី **ទឹង សុខា** បាននិយាយថា ខ្មែរក្រហមបានស្នើឲ្យប្រជាជននាំគ្នាចុះឈ្មោះ រួមទាំងមុខរបរ និងទីកន្លែងដែលធ្លាប់ស្នាក់នៅពីមុន។ លោកស្រីក៏បាននិយាយផងដែរថា ប្រជាជនដែលមានចំណេះដឹងត្រូវបានគេបញ្ជូនឲ្យទៅនៅក្នុងផ្ទះវែងមួយដែលបានសាងសង់ហើយជាស្រេចសម្រាប់ពួកគេក្នុងភូមិត្រពាំងអង្គ ចំណែកឯជនជាតិចិន ឬអ្នកស្រែចម្ការផ្សេងទៀតត្រូវបានស្នើឲ្យទៅរស់នៅឆ្ងាយពីទីនោះប្រមាណជា៥០ម៉ែត្រ។ បន្ថែមពីនេះ លោកស្រី **ទឹង សុខា** បានឃើញទាហាន **លន់ នល់** ដែលបានទៅរស់នៅក្នុងភូមិកោះលាវ ក៏ប៉ុន្តែពួកគេត្រូវបានប្ដូរទីតាំង ហើយលោកស្រីក៏មិនដែលបានឃើញពួកគេទៀតឡើយ។

ក្នុងអំឡុងនៃការស្នាក់ក្នុងភូមិថ្នល់ដាច់ លោកស្រី **ទឹង សុខា** បាននិយាយថា លោកស្រីបានចូលរួមកិច្ចប្រជុំចំនួនពីរដង។ កិច្ចប្រជុំលើកទីមួយ ត្រូវបានធ្វើនៅក្នុងភូមិកុមាររាជា ហើយត្រូវបានចូលរួមតែពី

សំណាក់ប្រជាជន១៧មេសាតែប៉ុណ្ណោះ។ កិច្ចប្រជុំនេះ ពិភាក្សាស្តីពីគោលនយោបាយបក្ស។ កិច្ចប្រជុំលើកទីពីរ គឺជាការ "ប្រជុំដ៏ធំមួយ" និងបានធ្វើឡើងនៅក្នុងភូមិថ្នល់ដាច់។ ក្នុងកិច្ចប្រជុំមួយនេះ ពួកគេបានពិភាក្សាអំពីជ័យជម្នះរបស់ខ្មែរក្រហម និងការបង្រាបពួក "ចក្រពត្តិនិយម" និងបក្សពួកទាំងអស់របស់ **លន់ នល់**។ អ្នកចូលរួមប្រជុំ ត្រូវតែជានាអះអាងថា បដិវត្តន៍ គឺខ្លាំងអស្ចារ្យ បើទោះបីជាពួកគេមិនមានអ្វីច្រើនសម្រាប់បរិភោគក៏ដោយ។ លោកស្រី **ទឹង សុខា** បានផ្តល់សក្ខីកម្មថា កិច្ចប្រជុំក៏បាននិយាយផងដែរអំពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្មែរក្រហមក្នុងការកំណត់រក "សត្រូវផ្ទៃសុីរូងផ្ទៃក្នុង" និង "បោសសម្អាត" ពួកគេចោល។ លោកស្រីបានរម្លឹកឡើងវិញថា មានទាហាននារីខ្មែរក្រហមម្នាក់ បានសួរលោកស្រីពីប្រវត្តិរូបនៅពេលកំពុងប្រជុំ។ បន្ទាប់មកទៀត មានការរាំរែកកំសាន្ត ជាមួយអ្នកសិល្បៈមួយចំនួនដែលគ្រប់គ្នាស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ។

### *ក.៣. ការជម្លៀសចេញពីខេត្តតាកែវ*

លោកស្រី **ទឹង សុខា** មិនអាចចងចាំបានច្បាស់លាស់ពីឆ្នាំដែលលោកស្រីបានឆ្លងកាត់ការជម្លៀសក្នុងលើកទីពីរនេះទេ ប៉ុន្តែលោកស្រីបានផ្តល់សក្ខីកម្មថា វាបានកើតឡើងមុនពេលរដូវភ្លៀងប្រហែលជាក្នុងខែកក្កដា ឬខែសីហា។ តាមឲ្យដឹងមក ខ្មែរក្រហមបានរៀបចំការប្រជុំមួយ ដើម្បីជូនដំណឹងដល់ប្រជាជនថាពួកគាត់ទាំងអស់នឹងត្រូវប្តូរទីតាំងទៅនៅភូមិថ្មីមួយទៀតដែលមានស្រូវអង្ករគ្រប់គ្រាន់។ ដោយការរំពឹងទុកថានឹងបានបរិភោគគ្រាន់បើជាងកន្លែងដែលកំពុងស្នាក់នៅ លោកស្រី **ទឹង សុខា** បានសម្រេចចិត្តធ្វើតាម "អង្គការ"។ លោកស្រី បានរំលឹកឡើងវិញពីរបៀបដែលប្រជាជនត្រូវបានគេញាត់បញ្ចូលទៅក្នុងឡានធំដែលគ្មានកៅអីអង្គុយ ដោយមិនដឹងថាពួកគាត់ត្រូវបញ្ជូនទៅទីណាពិតប្រាកដនោះទេ។ ឡានបានទៅដល់ខេត្តពោធិ៍សាត់នៅពេលយប់ ហើយខណៈដែលបម្រុងនឹងបញ្ជូនប្រជាជនទាំងនោះឲ្យឡើងលើរថភ្លើង លោកស្រីបានឮស្នូរបាញ់កាំភ្លើង។ លោកស្រីត្រូវបានប្រាប់ថា ស្នូរកាំភ្លើងនោះគឺបានបាញ់ទៅលើប្រជាជនមួយចំនួនដែលព្យាយាមចង់រត់។ រថភ្លើងបានឈប់នៅស្ថានីយគោកត្រុម ក៏ប៉ុន្តែវាមិនមែនជាទីកន្លែងដែលប្រជាជនរស់នៅទេ ពោលគឺដូចព្រៃរហោឋានអីចឹង។ លោកស្រីផ្តល់សក្ខីកម្មថា ក្រុមរបស់លោកស្រីបានរស់នៅក្នុងព្រៃក្នុងតំបន់នេះប្រហែលជាពីរទៅបីខែ ដោយបរិភោគដង្កូវខ្លួង ជន្លួនជាអាហារ និងសត្វល្អិតផ្សេងៗទៀត។ ក្រោយមកទៀត គាត់ត្រូវបានគេយកទៅភូមិស្រែឱ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ យោងតាមលោកស្រី **ទឹង សុខា** លោកស្រីទទួលរងនូវការលំបាកកាន់តែខ្លាំងក្នុងអំឡុងពេលនៃការជម្លៀសលើកទីពីរ បើប្រៀបនឹងការជម្លៀសលើកទីមួយ៖

> *ខ្ញុំត្រូវតែហូបជន្លេន...ដង្កូវប្រភេទអីក៏ដោយ ឲ្យតែអាចហូបបាន ហើយនៅពេលយើងបន្ទោរបង់មក គឺមិនដូចលាមកមនុស្សទេ ដូចលាមកស្វាអញ្ចឹង...យើងហូបស្លឹកថ្នឹងដែលជូរបំផុតទៅជាមានរសជាតិផ្អែម ព្រោះតែយើងឃ្លានខ្លាំងពេក។*

បន្ទាប់ពីបានទៅដល់ខេត្តបាត់ដំបងមិនយូរប៉ុន្មានផង លោកស្រី **ទឹង សុខា** បានបាត់បង់កូនស្រីម្នាក់ ព្រោះតែមិនមានអាហារបរិភោគគ្រប់គ្រាន់។ ខ្លួនប្រាណកូនរបស់គាត់បានក្លាយទៅជាហើម និងមានជម្ងឺរាក រូសធ្ងន់ធ្ងរ។ នាងបានស្លាប់កាលពីដើមឆ្នាំ១៩៧៦ ដោយសារតែគ្មានសេវាព្យាបាលសុខភាពត្រឹមត្រូវ។ ចំណែកឯ ប្អូនស្រីបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏បានស្លាប់ក្នុងអំឡុងពេលប្រហាក់ប្រហែលគ្នានេះដែរ។ ក្នុងឆ្នាំ១៩៧៨ ស្វាមីរបស់លោកស្រី ដែលលោកស្រីបានប្រាប់តុលាការថា ជាមនុស្សដែលមាន "សុខភាពទ្រុឌទ្រោមខ្លាំង" ជាមនុស្សដែល "មានការគិតច្រើន" មិនដែល "ស្តែងឲ្យឃើញពីការគិតរបស់គាត់" ឲ្យអ្នកដទៃដឹងនោះទេ ហើយ "មិនអាចទ្រាំទ្រនឹងស្ថានភាពដែលបានកើតឡើងក្នុងពេលនោះតទៅទៀតបាន" គាត់ក៏បានធ្វើអត្តឃាតខ្លួនឯង។

### *ក.៤. សេចក្តីថ្លែងពីទុក្ខសោក អត្តចរិត និងភាពអាចជឿជាក់*

លោកស្រី **ទឹង សុខា** បានស្តែងឲ្យឃើញពីអារម្មណ៍យ៉ាងរំជើបរំជួល និងយកចិត្តទុកដាក់ក្នុងការផ្តល់សក្ខីកម្មយ៉ាងពិស្តារជូនដល់អង្គជំនុំជម្រះ។ លោកស្រីមានភាពក្តុកក្តួលក្នុងចិត្ត នៅពេលដែលលោកស្រីបាននិយាយរ៉ាយរ៉ាប់អំពីការស្លាប់កូនស្រីអាយុបីឆ្នាំ និងការធ្វើអត្តឃាតរបស់ប្តីលោកស្រី។ នៅក្នុងសេចក្តីថ្លែងពីទុក្ខសោក លោកស្រីបានសង្ខេបពីសេចក្តីលំបាកវេទនាដ៏គួរឲ្យរន្ធត់ ដែលលោកស្រីបានទទួលរងក្នុងអំឡុងពេលធ្វើការជម្លៀសទាំងពីរលើក។ លោកស្រីបានរៀបរាប់អំពីស្ថានភាពនៃការជម្លៀសលើកទីពីរថាជាការរស់នៅក្នុង "គុកឥតជញ្ជាំង" ដោយបាននិយាយថា លោកស្រីបានទទួលរងនូវក្តី "សោកសង្រេងដ៏ធ្ងន់ធ្ងរមិនអាចកាត់ថ្លៃបាន"។

> *ហើយនៅពេលដែលកូននាងខ្ញុំស្លាប់ គឺជាពេលដែលខ្លោចផ្សាបំផុតក្នុងជីវិតរបស់នាងខ្ញុំដែលខ្ញុំស្ទើរតែមិនអាចបន្តជីវិតរស់នៅតទៅទៀតបាន នាងខ្ញុំឈឺចាប់ណាស់ស្ទើរឆ្កួតស្ទើរជា គេដាក់កូនខ្ញុំនៅក្នុងអង្រឹងមួយ ជាមួយមនុស្សស្លាប់៧នាក់ផ្សេងទៀត។ ខ្ញុំតក់ស្លុតខ្លាំងណាស់នៅពេលប្តីសម្លាប់ខ្លួន។ ខ្ញុំឃើញគាត់ព្យួរកគាត់នឹងខ្សែព្យួរនៅក្នុងផ្ទះ។ ខ្ញុំយំ...ខ្ញុំយំដោយគ្មានទឹកភ្នែក។*[3]

បន្ទាប់ពីរបបនេះផុតរលត់ទៅ លោកស្រី **ទឹង សុខា** បាននិយាយថា លោកស្រីបានបាត់បង់អស់នូវសមត្ថភាពធ្វើការងារ និងពិបាកទទួលទានដំណេក ដោយនិយាយថា៖ "ទុក្ខសោក និងការឈឺចាប់ទាំងនោះនៅតែអន្ទោលតាមប្រាណមិនព្រមផុតរលត់ទៅណាឡើយ...យើងមិនអាចប្រៀបធៀបដូចជាការលុបសំឡេងចេញពីកាសែតម៉ាញ៉េទេ។ ខ្ញុំនៅតែដេកស្រក់ទឹកភ្នែកនៅពេលនឹកឃើញរឿងរ៉ាវទាំងនេះ។"[4]

## ខ. សក្ខីកម្មរបស់លោកស្រី ពេជ ស្រីផល

កាលពីព្រឹកថ្ងៃពុធ ដើមបណ្តឹងរដ្ឋប្បវេណី **ពេជ ស្រីផល** (TCCP 108) បានចាប់ផ្តើមផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះ។ ដូចគ្នានឹងលោកស្រី **ទឹង សុខា** ដែរ លោកស្រី **ពេជ ស្រីផល** បានផ្តោតសំខាន់ក្នុងសក្ខីកម្មរបស់ខ្លួនស្តីពីការជម្លៀសទាំងពីរវគ្គ។ លោកស្រីក៏បានផ្តល់សក្ខីកម្មផងដែរ អំពីការសម្លាប់អតីតទាហាន **លន់ នល់** និងមន្ត្រីរដ្ឋការក្នុងរបបនេះ រួមទាំងបាននិយាយផងដែរពីគោលនយោបាយបក្ស។

### ខ.១. ស្ថានភាពមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

យោងតាមលោកស្រី **ពេជ ស្រីផល** ស្ថានភាពក្នុងទីក្រុងភ្នំពេញមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺមានភាព "វឹកវរច្របូកច្របល់"។ មានការភៀសខ្លួនចូលទីក្រុងភ្នំពេញយ៉ាងច្រើនកកកុញ។ តម្លៃថ្នាំ ម្ហូបអាហារ និងសម្ភារផ្សេងៗទៀតឡើងថ្លៃយ៉ាងគំហុក ដែលការឡើងថ្លៃនេះមិនអាចធ្វើឲ្យប្រជាជនមានលទ្ធភាពទិញបានឡើយ។ ផ្ទះរបស់លោកស្រី **ពេជ ស្រីផល** នៅក្បែរឃ្លាំងរំសេវ និងផ្សារដើមគរត្រូវភ្លើងឆេះ ពេលនោះហើយដែលប្រជាជនចាប់ផ្តើមស្វះស្វែងខ្លាំងរុករកម្ហូបអាហារទុកបរិភោគ។ ស្នូរគ្រាប់កាំភ្លើងធំ និងគ្រាប់បែកដៃ បានឮលាន់រំពងពីគ្រប់ច្រកល្ហកទាំងអស់ក្នុងទីក្រុង។ ឪពុករបស់លោកស្រី គឺជាគិញឲ្យរបប **លន់ នល់** ហើយក៏ជា **ស៊ី. អាយ. អេ** ផងដែរ។ គាត់បានប្រាប់លោកស្រីឲ្យពួននៅក្នុងផ្ទះពេលមានការទម្លាក់គ្រាប់បែក។ មានអ្នករងរបួស និងអ្នកជម្ងឺជាច្រើនសន្ធឹកសន្ធាប់ក្នុងមន្ទីរពេទ្យ ហើយបុគ្គលិកពេទ្យ បូករួមទាំងស្វាមីរបស់លោកស្រី[5] មានការមមាញឹកមិនអាចដកឃ្លាមកផ្ទះបាន។

### ខ.២. ការជម្លៀសចេញពីទីក្រុងភ្នំពេញ

យោងតាមលោកស្រី **ពេជ ស្រីផល** នៅវេលាប្រហែលជាម៉ោង១០ព្រឹកថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ លោកស្រីបានឃើញទាហានខ្មែរក្រហម ពាក់ឯកសណ្ឋានពណ៌ខ្មៅ និងពាក់ស្បែកជើងសង្រែក ពាក់គ្រាប់រ៉ូកែត បេ-៤០ និងស្ពាយកាំភ្លើង។ លោកស្រីក៏ឃើញមានឡានទាហាន (ហ្សីប) ដែលពោរពេញដោយទាហានស្លៀកពាក់ឯកសណ្ឋានពណ៌គគីរនៅតាមផ្លូវ។ ខ្មែរក្រហមបានផ្សព្វផ្សាយពីជ័យជម្នះរបស់ខ្លួន និងបាននិយាយថា ពួកគេនឹងធ្វើឲ្យប្រទេសជាតិមានសន្តិភាពពេញលេញមកវិញ។ ប្រជាជននាំគ្នាដោះអាវពណ៌សរបស់ខ្លួន ហើយគ្រវីឡើងលើដោយសេចក្តីរីករាយ និងស្វាគមន៍ចំពោះជោគជ័យមួយនេះ។ ភ្លាមៗមកទៀតខ្មែរក្រហមបាន ធ្វើការប្រកាសតាមរយៈឧបករណ៍បំពងសំឡេង ស្នើឲ្យប្រជាជនទាំងអស់ចាកចេញពីទីក្រុងចំនួនបីថ្ងៃ ដើម្បីរៀបចំទីក្រុងភ្នំពេញឡើងវិញ ហើយក៏ដូចជារៀបចំខ្លួនទប់ទល់នឹងការទម្លាក់គ្រាប់បែកពីទាហានអាមេរិកាំង។ លោកស្រី **ពេជ ស្រីផល** បាននាំគ្នាចាកចេញជាមួយនឹងជីដូនវ័យចំណាស់ម្នាក់ រួមជាមួយនឹងប្អូនស្រីរបស់គាត់ ខណៈដែលស្វាមីលោកស្រីកំពុងបន្តស្នាក់នៅមន្ទីរពេទ្យ។ គាត់បានសម្រេចចិត្តឈប់រង់ចាំស្វាមី ឪពុក និងបងប្អូនបង្កើតផ្សេងៗទៀតបន្ទាប់ពីដើរទៅដល់ស្ទឹងមានជ័យ ដែលជាទីតាំងមួយនៅជាយក្រុងបន្តិច តែមិនឃើញមានអ្នកណាម្នាក់បង្ហាញខ្លួនឡើយ។

យោងតាមលោកស្រី **ពេជ ស្រីផល** ប្រហែលជាម៉ោង៣ រសៀល ខ្មែរក្រហមបានប្រកាសជូនដំណឹងដល់ទាហាន **លន់ នល់** ឲ្យដាក់អាវុធចុះ និងចូលសារភាព។ លោកស្រីបានរម្លឹកថា មានអាវុធច្រើនសន្ធឹកសន្ធាប់បោះចោលរាយពាយ និងខ្លះគរជាពំនូកនៅតាមដងផ្លូវ។ រាល់អ្នកដែលស្លៀកសំលៀកបំពាក់ឯកសណ្ឋានទាហានត្រូវបានស្នើឲ្យដោះចេញ នៅសល់តែខោខ្លី។

ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយថា នៅតាមផ្លូវ លោកស្រីឃើញអ្នកដែលប្រកែកមិនព្រមដោះសំលៀកបំពាក់ឯកសណ្ឋាននោះចេញត្រូវខ្មែរក្រហមវ៉ៃ។ មានប្រជាជនជាច្រើន បូករួមទាំងចាស់ជរា និងអ្នកជម្ងឺដែលមានព្យួរសេរ៉ូមជាប់ដៃបាននាំគ្នាដើរចេញពី "ពេទ្យរូស្ស៊ី" ឬមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត។ អ្នកជម្ងឺខ្លះបានស្លាប់នៅនឹងគ្រែពេទ្យ ហើយពេលនោះ ខ្មែរក្រហមបានប្រាប់ឲ្យនាំគ្នាចេញដោយមិនខ្វល់ពីអ្នកជម្ងឺអ្វីទាំងអស់។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យពួកគេធ្វើដំណើរទៅណាក្រៅពីច្រកស្ពានស្ទឹងមានជ័យឡើយ។ លោកស្រីក៏

បានរម្លឹកឡើងវិញថា ទាហានទាំងនោះបានបាញ់ឡើងលើ ដើម្បីគំរាមប្រជាជនមិនឲ្យត្រឡប់ក្រោយ បើមិនដូច្នេះទេ ពួកគេអាចនឹងត្រូវបាញ់សម្លាប់ចោល។ ក្នុងអំឡុងពេលនៃការជម្លៀស ទាហានខ្មែរក្រហមមិនបានផ្ដល់ថ្នាំសង្កូវ ទឹក ម្ហូបអាហារ ឬទីជម្រកដល់ប្រជាជនទេ។ ប្រជាជនបាននាំគ្នាដើរដល់ពេលយប់ត្រឹមណាដេកត្រឹមហ្នឹង ពោលគឺនៅតាមបណ្ដោយដងផ្លូវ។ លោកស្រី **ពេជ ស្រីផល** បានផ្ដល់សក្ខីកម្មថា កូនប្រុសតូចដែលទើបនឹងកើតរបស់គាត់បានស្លាប់ក្នុងអំឡុងពេលជម្លៀស ព្រោះតែលោកស្រីមិនមានទឹកដោះដើម្បីបំបៅកូន។

ក្រោយពេលបានទៅដល់ចម្ការដូង លោកស្រី **ពេជ ស្រីផល** បានជួបជុំជាមួយឪពុក និងប្ដីរបស់គាត់ ហើយទាំងអស់គ្នាបាននាំគ្នាធ្វើដំណើរទៅកាន់ភូមិព្រៃត្រប់។ លោកស្រីបានផ្ដល់សក្ខីកម្មថា លោកស្រី បានឮការប្រកាសតាមឧបករណ៍បំពងសំឡេងជូនដំណឹងដល់អតីតមន្ត្រីរដ្ឋការ គ្រូបង្រៀន និងពេទ្យអាចត្រឡប់ទៅកាន់តួនាទីរបស់ខ្លួនដូចដើមនៅទីក្រុងភ្នំពេញ និងត្រូវចុះឈ្មោះជាមុនសិន។ មានមន្ត្រីបម្រើការសាធារណៈរបស់របបមុនជាច្រើនបាននាំគ្នាចុះឈ្មោះ ហើយលោកស្រីសង្កេតឃើញថា ពួកគេទាំងនោះត្រូវ បានយកចេញទៅ ដោយមិនបាននាំសមាជិកក្រុមគ្រួសារខ្លួនទៅជាមួយឡើយ។ ចំណែកឯ ឪពុករបស់លោកស្រីមិនបានទៅចុះឈ្មោះនឹងគេទេ ដោយសារតែគាត់មានជម្ងឺនៅពេលនោះ។

បន្ទាប់ពីចាកចេញពីចម្ការដូង ខ្មែរក្រហមបានដកហូតយកកម្មសិទ្ធិផ្ទាល់ខ្លួនរបស់លោកស្រីនៅត្រង់ប៉ុស្ដិ៍ត្រួតពិនិត្យ និងបានប្រាប់លោកស្រីថា គ្រប់គ្នាត្រូវតែលះបង់នូវរាល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់ បើមិនដូច្នោះទេ ពួកគេនឹងត្រូវចោទប្រកាន់ថា ជាពួកសក្ដិភូមិ និងជាសត្រូវរបស់អង្គការ។ លោកស្រីក៏បានឃើញច្បាស់នឹងភ្នែក ដែលខ្មែរក្រហមប្រមូលយកប្រាក់ដែលយកបានពីប្រជាជនទៅដុតចោលផងដែរ។

### *ខ.៣. ភូមិព្រៃត្រប់ និងការកាប់សម្លាប់អតីតមន្ត្រីរដ្ឋការ លន់ នល់*

នៅពេលដែលលោកស្រី **ពេជ សុផល** បានទៅដល់ភូមិព្រៃត្រប់កាលពីចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ ប្រធានសហករណ៍បានណែនាំឲ្យអ្នកជម្លៀសទាំងអស់បែងចែកគ្នាជាក្រុម និងនៅផ្ទះផ្សេងៗគ្នា។ មួយសប្ដាហ៍ក្រោយមកទៀត ខ្មែរក្រហមបានហៅ "ប្រជាជន១៧មេសា" ទាំងអស់ប្រជុំដើម្បីធ្វើការចុះឈ្មោះ និងមុខរបរពីមុនរបស់ពួកគេ។ ខ្មែរក្រហមក៏បានសួរនាំអ្នកដែលមានស្បែកសថ្លាថា តើពួកគេជាជនជាតិចិន ឬវៀតណាម? មានមន្ត្រីរដ្ឋការសាធារណៈចំនួន៦០នាក់បានចុះឈ្មោះ បូករួមទាំងអ៊ំប្រុស និងបងប្រុសជីដូនមួយម្នាក់ទៀតរបស់លោកស្រីផងដែរ ដែលពេលនោះពួកគេបានចុះឈ្មោះ ថាជាអតីតទាហាន។ ទោះជាយ៉ាងណា ឪពុក និងស្វាមីរបស់លោកស្រីមិនបានចុះឈ្មោះនឹងគេទេ ព្រោះពួកគាត់មិនចង់រស់នៅបែកគ្នា។ ពីរថ្ងៃក្រោយមក អ្នកចុះឈ្មោះទាំងនោះត្រូវបានដឹកតាមឡានត្រាក់ធំៗ ដើម្បីត្រឡប់ទៅបំពេញការងារដើមរបស់ពួកគេនៅទីក្រុងភ្នំពេញ។ បន្ទាប់ពីបានរកឃើញថា ឪពុករបស់លោកស្រីមានកូនវិទ្យុនៅជាប់ខ្លួន ខ្មែរក្រហមបានស្នើឲ្យគ្រួសារលោកស្រីត្រឡប់មកភ្នំពេញវិញ បើទោះជាមិនបានចុះឈ្មោះក៏ដោយ។ នៅតាមផ្លូវត្រឡប់មកភ្នំពេញវិញ មានបុរសជិះរទេះគោម្នាក់បានលួចប្រាប់លោកស្រីឲ្យនាំគ្នារត់គេចខ្លួន ព្រោះអ្នកផ្សេងទៀតដែលបានដឹកមកមុនៗ គឺមិនត្រូវបានគេបញ្ជូនមកភ្នំពេញវិញទេ តែគេបានយកក្រុមនោះទៅសម្លាប់។ ក្រោយឮដូចនេះ ក្រុមគ្រួសាររបស់លោកស្រីបាននាំគ្នាគេចខ្លួនចូលក្នុងព្រៃ។ ពួកគេបាននាំគ្នាដើរកាត់ព្រៃរយៈពេល៧យប់ និងបានជួបឪពុកក្មេករបស់គាត់នៅភូមិព្រៃក្រឡាញ់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ទោះជាយ៉ាងនេះក្ដី ពួកគាត់បានស្នាក់នៅទីនោះបានតែ៥ថ្ងៃ ពីព្រោះឪពុកក្មេករបស់លោកស្រីមិនអាចលាក់បាំងពួក

គេបានតទៅទៀត។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា នៅទីបំផុត សមាជិកក្រុមគ្រួសាររបស់គាត់ទាំងអស់បានបង្ហាញខ្លួនដល់អង្គការ និងបានប្រាប់ពីការយល់ព្រមដើរតាមមាគ៌ារបស់បក្ស។

## ខ.៤. ការអប់រំកែប្រែខ្លួន និងការស្នាក់នៅជាបណ្ដោះអាសន្នលើភ្នំស្ទុក

យោងតាមលោកស្រី **ពេជ ស្រីផល** បន្ទាប់ពីបានប្រគល់ខ្លួនឲ្យខ្មែរក្រហម ក្រុមគ្រួសារលោកស្រី និងប្រជាជន១៧មេសាចំនួន៥០នាក់ផ្សេងទៀត ត្រូវបានបញ្ជូនទៅកាន់ភ្នំស្ទុក នៅខេត្តកំពង់ស្ពឺ ដើម្បីលត់ដំចិត្ត និងកែប្រែខ្លួន។ លោកស្រីបានពន្យល់ថា ពេលនោះ "ប្រជាជនថ្មី" ត្រូវគេបានសង្កេតតាមដានក្នុងនាមជាជនក្បត់ ជាពួកនាយទុន ឬពួកសក្តិភូមិដែលមាននិន្នាការតាម **លន់ នល់** ឬជាពួក **ស៊ី. អាយ. អេ**។ កាលនៅលើភ្នំ ពួកគេគ្មានទីជម្រក គ្មានម្ហូបអាហារ ទឹកផឹក ឬថ្នាំសង្កូវអ្វីទាំងអស់។ ពួកគេអាចមានជីវិតរស់នៅបានដោយសារបរិភោគទឹកសន្សើម និងបរិភោគស្លឹកឈើ និងសត្វជ្រូកព្រៃ។ អ្នកដែលមានសាច់ញាតិនៅក្នុងភូមិខ្លះ បានលួចចុះពីលើភ្នំ ដើម្បីមករកអង្ករសម្រាប់ដាំបាយហូប ហើយអ្នកដែលបានលួចចុះមកភូមិខ្លះ ត្រូវបានខ្មែរក្រហមបាញ់ស្លាប់។ ពីរខែក្រោយមក មានតែមនុស្សស្គមស្គាំងចំនួន២០នាក់តែប៉ុណ្ណោះនៅសេសសល់។ លោកស្រី **ពេជ ស្រីផល** បាននិយាយថា៖

> *អ្នកទាំង២០នាក់ដែលនៅសេសសល់ គឺសុទ្ធតែមានរូបរាងស្គមកំព្រឹង។ សក់ពួកយើងដុះឡើងវែងដូចមនុស្សព្រៃ និងសុទ្ធតែចៃព្រោះយើងអត់មានទឹកអីណាមុជទេ សូម្បីតែទឹកផឹកក៏រកមិនចង់បានផង ហើយក្បាលជង្គង់យើងឡើងធំជាងក្បាលទៅទៀត។ អត់មានអីហូបទេ ហូបតែស្លឹកឈើដើរបេះបានពីព្រៃ។*[6]

លោកស្រី **ពេជ ស្រីផល** បាននិយាយថា នៅពេលនោះមានការជូនដំណឹងពីអង្គការថា "ឥលូវហ្នឹងសមមិត្តទាំងអស់គ្នាបានលត់ដំកែប្រែខ្លួនរួចរាល់ហើយ អីចឹងអាចចុះពីលើភ្នំទៅធ្វើការងារអីហ្នឹងគេបាន"។[7] នៅពេលដែលពួកគេចុះពីលើភ្នំ ពួកគេបានឡើងជិះឡានធំចំនួនពីរគ្រឿង ដែលនៅចាំទទួលហើយជាស្រេចជាមួយ "ប្រជាជនថ្មី" ដើម្បីត្រឡប់មកកាន់ភ្នំពេញវិញ។ ជាសរុបមក ប្រជាជនទាំងនោះមានប្រហែលជា៦០ នាក់ ។

## ខ.៥. ការជម្លៀសវគ្គទីពីរទៅកាន់ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

ដើមបណ្ដឹងរដ្ឋប្បវេណីបានរ៉ាយរ៉ាប់ថា មកដល់ភ្នំពេញ ពួកគាត់បានស្នាក់នៅពីរយប់ក្នុងស្ថានីយរថភ្លើង។ នៅពេលក្បាលរថភ្លើងបានមកដល់ ប្រជាជនទាំងនោះត្រូវបានបញ្ជាឲ្យនាំគ្នាឡើងរថភ្លើង។ យ៉ាងហោចណាស់ មានទាហានខ្មែរក្រហមបីនាក់ប្រដាប់ដោយកាំភ្លើងនៅយាមតាមទូនីមួយៗ។ មានប្រជាជនមួយចំនួនបានស្លាប់ ដោយសារតែភាពហេវហត់ខ្លាំងពេក ហើយមានប្រជាជនម្នាក់ត្រូវបានបាញ់សម្លាប់ នៅក្រោយពេលដែលគាត់បានបត់ជើងតូចក្នុងទូរថភ្លើង។ រថភ្លើងបាននាំពួកគេទៅដល់ខេត្តកំពង់ឆ្នាំង ជាកន្លែងដែលអ្នកជម្លៀសទាំងឡាយធ្វើស្រែចម្ការ និងសាងទំនប់ប្រឡាយ។ លោកស្រី **ពេជ ស្រីផល** បាននិយាយថា បន្ទាប់ពីបានរស់នៅក្នុងខេត្តកំពង់ឆ្នាំងប្រហែលជាមួយឆ្នាំ លោកស្រី និងប្រជាជន១៧មេសាផ្សេងទៀត ត្រូវបានបញ្ជូនជាថ្មីម្តងទៀតទៅកាន់ខេត្តពោធិ៍សាត់។ ទោះបីជាលោកស្រីមិនបានដឹងថា មានប៉ុន្មានលើកទេ

ដែលខ្មែរក្រហមដឹកអ្នកជម្លៀសទៅខេត្តពោធិ៍សាត់ពេលនោះក៏ដោយ ក៏លោកស្រីបានស្ថិតក្នុងចំណោមហ្វូងមនុស្សមួយក្រុមដំបូងគេដែលត្រូវបានដឹកចេញទៅដែរ។ នៅថ្ងៃដែលលោកស្រីធ្វើដំណើរ "មានឡានធំ៦បី... ហើយអ្នកជម្លៀសទៅពោធិ៍សាត់ពេលនោះ សរុបយ៉ាងហោចណាស់ក៏មាន២,០០០ នាក់ដែរ"។[8]

### ខ.៦. *សហករណ៍នៅវត្តល្វង នៅខេត្តពោធិ៍សាត់*

នៅពោធិ៍សាត់ លោកស្រី **ពេជ ស្រីផល** ត្រូវបានចាត់ឲ្យធ្វើការនៅក្នុងអង្គភាពបណ្ដុះកូនឈើនៅសហករណ៍វត្តល្វង រីឯស្វាមីលោកស្រីត្រូវបានបំបែកចេញឲ្យទៅធ្វើការនៅអង្គភាពភ្ជួររាស់។ ដោយឡែកឪពុកម្ដាយរបស់លោកស្រី ត្រូវបានបញ្ជូនទៅកាន់ទីតាំងផ្សេងទៀត។ យោងតាមលោកស្រី **ពេជ ស្រីផល** អ្នកមើលការខុសត្រូវរួមក្នុងសហករណ៍វត្តល្វងមានឈ្មោះ តា **សែន** យាយ **កប** តា **មាន** និងយាយ **ភួន**។ ដោយឡែកចំពោះថ្នាក់ដឹកនាំផ្សេងៗទៀត លោកស្រីបាននិយាយថា "ខ្ញុំបានឮគេនិយាយពី តា **ម៉ុក** លោក **អៀង សារី** លោក **ខៀវ សំផន** និង លោក **នួន ជា** តែមិនដែលបានជួបពួកគាត់ទេ"។[9]

ដើមបណ្ដឹងរដ្ឋប្បវេណីបានរម្លឹកឡើងវិញថា ពួកគេត្រូវបានប្រាប់ឲ្យខិតខំធ្វើការបង្កបង្កើនផល ហើយនៅពេលកំពុងស្ទូង ឬច្រូតស្រូវ មានទាហានពីរនាក់ឈរកាន់ខ្សែលួសនៅសងខាងស្រែវាត់ចុះក្រោមឡើងលើឲ្យអ្នកនៅក្នុងស្រែឱនងើបតាមការបញ្ជា ដោយការវាត់ខ្សែចុះឡើងរបស់ពួកគេដោយមានការផ្ដុំកញ្ចែផងដែរ ហើយអ្នកដែលស្ទូងមិនទាន់ ខ្សែលួសនោះនឹងវាត់ត្រូវភ្នែកពួកគេជាមិនខាន។ ដោយឡែក ស្ថានភាពរបបអាហារដែលត្រូវទទួលវិញ លោកស្រីបាននិយាយថា អង្ករមួយកំប៉ុងត្រូវបានផ្ដល់ដល់ប្រជាជន៣០នាក់ ដូច្នេះពួកគេម្នាក់ៗអាចត្រឹមតែទទួលបានបបររាវដូចទឹកតែប៉ុណ្ណោះសម្រាប់បរិភោគ។ ទាក់ទងនឹងស្ថានភាពអ្នកជម្ងឺវិញ លោកស្រី **ពេជ ស្រីផល** បានរម្លឹកឡើងវិញថា នៅពេលលោកស្រីកើតដំបៅ និងមានខ្ទុះនៅជើងទាំងសងខាងរបស់គាត់ អ្នកស្រីត្រូវបានប្រាប់ថា រាល់អ្នកជម្ងឺនឹងមិនត្រូវទទួលបានរបបអាហារទេ ព្រោះតែពួកគេមិនអាចធ្វើការបាន។ អ្នកដែលបានធូរស្បើយពីជម្ងឺមិនទាន់បានស្រួលបួលផង ក៏ត្រូវតែត្រឡប់ទៅធ្វើការវិញដែរ បើមិនដូច្នេះទេ ពួកគេនឹងអាចត្រូវបានកំទេច ដោយលោកស្រីបានពន្យល់ថា ពាក្យ "កំទេច គឺមានន័យថា សម្លាប់"។[10]

ដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នានូវឧទាហរណ៍ខុសៗគ្នាចំពោះការដាក់ទណ្ឌកម្ម។ កាលពីចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ លោកស្រី **ពេជ ស្រីផល** ត្រូវបានគេចាប់បាបនៅពេលកំពុងលួចស្រូវ និងត្រូវបានខ្មែរក្រហម "ដាក់ទណ្ឌកម្មឲ្យរែកដីឲ្យបាន២០០អម្រែកក្នុងមួយថ្ងៃ"។[11] លោកស្រីបានសន្លប់ដោយសារអស់កម្លាំងខ្លាំងពេក ហើយនៅពេលនោះពួកគេបានយកទឹកជះលើគាត់ដើម្បីឲ្យដឹងខ្លួនវិញ។ ក្រោយពីនោះ គេបានយកគាត់ទៅសម្លាប់ តែទោះជាយ៉ាងណា លោកស្រីបានពន្យល់ទាំងភាពស្រពិចស្រពិលថា មានបុរសវ័យចំណាស់ម្នាក់បានជួយសម្រួល ដើម្បីសង្គ្រោះរំដោះយកលោកស្រីចេញទៅ ដោយបុរសនោះបានមកប្រាប់ដល់អ្នកដែលនាំខ្លួនលោកស្រីទៅថា "បញ្ហាត្រូវវាបានដោះស្រាយហើយ"។[12] លោកស្រីក៏បានឃើញក្រុមស្ត្រីមួយចំនួនមកពីភូមិភាគបូព៌ា មានចងកនឹងក្រមាពណ៌ខៀវ។ ពួកគេត្រូវបានគេដាក់ច្រវ៉ាក់ និងបណ្ដើរជាជួរទៅកាន់ទំនប់ទឹក ហើយនាពេលនោះមានចុងភៅម្នាក់បានលួចប្រាប់លោកស្រីថា កុំឲ្យសេពគប់ជាមួយពួកគេ ព្រោះប្ដីរបស់ស្ត្រីទាំងនោះត្រូវបានគេសម្លាប់អស់ហើយ ហើយពួកគេក៏នឹងត្រូវសម្លាប់ដូចគ្នាដែរ។

លើសពីនេះទៀត កងឈ្លបបានដាក់ទារុណកម្មដល់គូសង្សារមួយគូ គឺមិត្ត **សោម** ហើយនិងមិត្ត **នី** ដោយបានចោទប្រកាន់ថា ពួកគេទាំងពីរមាន "គំហុសសីលធម៌"។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា "អ្វីដែលខ្ញុំបានឃើញ គឺមិត្ត **សោម** ត្រូវបានគេវះពោះជាមួយនឹងកាំបិតកាត់ថ្នាំជក់ ហើយពួកគេក៏យកកាំបិតនោះទៅអារកមិត្ត **នី** ទៀត។ ខ្ញុំឃើញដោយផ្ទាល់ភ្នែក គ្មានអ្នកណាប្រាប់ខ្ញុំទេពីរឿងរ៉ាវទាំងអស់នេះ"។[13]

### *ខ.៧. សេចក្តីថ្លែងការណ៍ពីទុក្ខសោក អត្តចរិត និងភាពជឿជាក់*

ដើមបណ្តឹងរដ្ឋប្បវេណី **ពេជ ស្រីផល** ហាក់ដូចជាមានចរិតស្មោះត្រង់ និងមានទំនុកចិត្តនៅពេលកំពុងផ្តល់សក្ខីកម្ម បើទោះណាជាគាត់មិនបានចាំកាលបរិច្ឆេទពិតប្រាកដ ចំពោះឧទាហរណ៍ដែលគាត់បានលើកឡើងមួយចំនួនក្នុងពេលសួរដេញដោលពីភាគី។

លោកស្រី **ពេជ ស្រីផល** បានអាននូវសេចក្តីថ្លែងពីទុក្ខសោករបស់ខ្លួន ដែលបានរៀបចំហើយជាស្រេច។ លោកស្រីបាននិយាយថា៖ "ខ្ញុំបានបាត់បង់អ្វីៗទាំងអស់ នៅសល់តែការគ្រាំគ្រាទាំងផ្លូវកាយ និងផ្លូវចិត្តរកអ្វីប្រៀបផ្ទឹមមិនបាន។ ភាពរន្ធត់តក់ស្លុត គឺនៅតែតាមបន្លាចខ្ញុំរហូតដល់សព្វថ្ងៃ៖ បទឧក្រិដ្ឋនេះបានបំផ្លិចបំផ្លាញទាំងអនាគតរបស់នាងខ្ញុំ ក្រុមគ្រួសារនាងខ្ញុំទាំងមូល ព្រមទាំងប្រជាពលរដ្ឋកម្ពុជាទាំងអស់"។[14] លោកស្រី ក៏បានរាយឈ្មោះសមាជិកគ្រួសារ និងសាច់ញាតិរបស់គាត់ដែលបានបាត់បង់ជីវិតក្នុងរបបនេះ រួមបញ្ចូលទាំងប្អូនប្រុសអាយុ១៤ឆ្នាំរបស់គាត់ ដែលត្រូវបានគេយកទៅសម្លាប់ដោយសារលួចផ្លែល្ពៅមួយផ្លែ។ បន្ថែមពីនេះ ឪពុករបស់លោកស្រី និងបងៗបានស្លាប់ ដោយសារធ្វើការធ្ងន់ពេក និងខ្វះថ្នាំសង្កូវព្យាបាលនៅពេលធ្លាក់ខ្លួនឈឺ។ លោកស្រីបញ្ជាក់ថា ស្រមោលអតីតកាលនៅតែតាមលងរូបគាត់។ លោកស្រីនៅតែចងចាំមិនភ្លេចនូវបទពិសោធន៍ដ៏ឈឺផ្សារបស់មិត្តកម្សត់កម្ររបស់គាត់ម្នាក់ ដែលបានស្ថិតក្នុងចំណោមស្ត្រី១៩នាក់ផ្សេងទៀតដែលប្រធានសហករណ៍ ឬប្រធានតំបន់យកទៅរំលោភ។ លោកស្រីបានធ្វើការស្នើសុំយ៉ាងជាក់លាក់ទៅកាន់តុលាការ ដើម្បីធ្វើការពិចារណាក្នុងការផ្តល់សំណងជាសមូហភាពផ្សេងៗដល់ជនរងគ្រោះ រួមមានដូចជាទម្រង់នៃការសាងសង់ចេតិយ ឬបង្កើតជាមជ្ឈមណ្ឌលវេជ្ជសាស្ត្រដើម្បីជួយគាំទ្រសុខភាពផ្លូវកាយ និងផ្លូវចិត្តដល់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

## គ. សក្ខីកម្មរបស់លោក គឹម វណ្ណី

ដើមបណ្តឹងរដ្ឋប្បវេណី **គឹម វណ្ណី** (TCCP 59) មានស្រុកកំណើតនៅស្រុកអង្គរជ័យខេត្តកំពត។ ក្នុងអំឡុងរបប **លន់ នល់** គាត់បានរស់នៅម៉ុំស្ពានជ្រោយចង្វារ ស្រុកមុខកំពូល ដែលមានទីតាំងមិនឆ្ងាយប៉ុន្មានពីទីក្រុងភ្នំពេញ។ នៅថ្ងៃទី១៦ ខែមេសា លោក **គឹម វណ្ណី** និងក្រុមគ្រួសាររបស់គាត់បាននាំគ្នាចូលមកទីក្រុងភ្នំពេញសំដៅទៅផ្ទះរបស់អ៊ំប្រុសរបស់គាត់ដែលមានទីតាំងនៅម៉ុំសន្ធរមុខ។ ដូចភាគីរដ្ឋប្បវេណីឯទៀតៗដែលបានផ្តល់សក្ខីកម្មក្នុងសប្តាហ៍នេះដែរ លោក **គឹម វណ្ណី** បានចែករំលែកនូវរឿងរ៉ាវផ្ទាល់ខ្លួនដែលបានជួបប្រទះ ស្តីពីស្ថានភាពក្នុងទីក្រុងភ្នំពេញនាពេលវ៉ៃប្រហារដណ្តើមយកទីក្រុងទាំងមូល និងសេចក្តីទុក្ខលំបាកផ្សេងៗដែលក្រុមគ្រួសារលោកបានជួបប្រទះនៅពេលក្រោយមកទៀត។ មានតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងភាគីសហព្រះរាជអាជ្ញា ដែលបានធ្វើការសួរដេញដោលលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

### គ.១. ការដួលរលំនៃទីក្រុងភ្នំពេញ

លោក **គីម វណ្ណី** បានរម្លឹកឡើងវិញថា មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរបស់ **លន់ នល់** បានតស៊ូប្រយុទ្ធជាមួយនឹងកងទ័ពខ្មែរក្រហមយ៉ាងស្វិតស្វាញ។ ការវាយប្រហារដ៏ក្តៅគគុក ក្នុងអំឡុងពេលល្ងាចថ្ងៃទី១៦ ខែមេសា អាចធ្វើឲ្យលាន់ឮសំឡេងសព្វទិសទីជុំវិញទីក្រុង។ មិនមានសមាជិកគ្រួសារលោកណាម្នាក់បានទទួលរងរបួសទេ ពីព្រោះពួកគេបានទៅសម្ងំលាក់ខ្លួននៅក្នុងលេនដ្ឋានដែលបានជីកនៅក្រោមផ្ទះ។

នៅពេលដែលគាត់បានភ្ញាក់ឡើងនៅពេលព្រឹកបន្ទាប់ គឺថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានឮប្រជាជនបាននាំគ្នាស្រែកអបអរសាទរ និងហ៊ោកញ្ជ្រៀវ ដោយបាននិយាយថា ខ្មែរក្រហមបានរំដោះទីក្រុងភ្នំពេញបានហើយ។ គាត់ក៏បានរម្លឹកផងដែរថា មានទាហានខ្មែរក្រហមជាច្រើនបានដើរល្បាតតាមដងផ្លូវក្នុងទីក្រុងភ្នំពេញ។ គាត់បានពន្យល់ថា គាត់មិនយល់ការច្បាស់លាស់ពីស្ថានភាពដែលកំពុងតែកើតឡើងនោះទេ ពីព្រោះតែគាត់នៅពេលនោះ គាត់មានអាយុតិចនៅឡើយ ប៉ុន្តែគាត់យល់ថា វាជាការគួរឲ្យរំភើប និងសប្បាយពេលឃើញប្រជាជនគ្រវីទង់ជ័យពណ៌ស ឬក្រណាត់ពណ៌ស ដើម្បីជាការស្វាគមន៍ដល់ការមកដល់របស់ខ្មែរក្រហម។ គាត់ក៏បានចូលរួមជាមួយពួកគេផងដែរ ដោយបានដោះអាវសិស្សសាលារបស់គាត់ ហើយគ្រវីជាមួយនឹងគេឯងផ្សេងៗទៀតដែរ។ យោងតាមលោក **គីម វណ្ណី** នៅខណៈពេលនោះ កងទ័ពខ្មែរក្រហមមួយរូបបានដើរចេញពីក្បួនកងទ័ពដែលបានកំពុងដើរល្បាតលើដងផ្លូវ ហើយស្រាប់តែបានបាញ់អ៊ំប្រុសរបស់គាត់ដែលមានស្លៀកពាក់ឯកសណ្ឋានកងទ័ព (ទាហាន **លន់ នល់**) និងទើបតែដើរចេញពីឡានហ្ស៊ីបរបស់គាត់។ ទាហានខ្មែរក្រហមបាននិយាយថា "ហ្នឹងហើយពួកអាក្បត់ ទាល់តែអញ្ចឹង!"។ ចាប់តាំងពីមានហេតុការណ៍នេះកើតឡើងមក ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់បានគិតក្នុងចិត្តថា ខ្មែរក្រហមជឿជាក់ថា "ឲ្យតែជាសត្រូវគឺខ្មែរក្រហមត្រូវតែសម្លាប់ទាំងអស់"។[15]

### គ.២. ការជម្លៀសចេញពីទីក្រុងភ្នំពេញ

បើតាមការចងចាំរបស់លោក **គីម វណ្ណី** ប្រហែលជានៅម៉ោង៩ពេលព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានជូនដំណឹងតាមឧគ្ឃោសនាស័ព្ទប្រាប់ថា គ្រប់គ្នាត្រូវតែចាកចេញពីទីក្រុងក្នុងរយៈពេលបីថ្ងៃ ដើម្បីចៀសវាងការទម្លាក់គ្រាប់បែកពីពួកអាមេរិកាំង។ គាត់ និងគ្រួសារ ក៏បាននាំគ្នាចាកចេញពីទីក្រុងភ្នំពេញ។ លោក **គីម វណ្ណី** បានឃើញសាកសពមនុស្សដេកស្លាប់ និងមានសភាពហើមដេកតាមបណ្តោយផ្លូវទៅកាន់ស្ពានជ្រោយចង្វារ ហើយគាត់បានសន្និដ្ឋានថា ការស្លាប់នេះបណ្តាលមកពីការវាយប្រហាររវាងទាហាន **លន់ នល់** និងទាហានខ្មែរក្រហម។ គាត់ក៏បានឃើញមានអ្នករងរបួសផងដែរ ខ្លះមានរុំប៉ង់ស៊ីម៉ង់ ឯខ្លះទៀតមានព្យួរសេរ៉ូមនៅនឹងដៃ។ ទោះជាយ៉ាងនេះក្តី លោក **វណ្ណី** មិនបានយកចិត្តទុកដាក់ចំពោះពួកគេទេ ដោយសារតែគាត់មិនចង់វង្វេងពីក្រុមគ្រួសាររបស់គាត់ និងត្រូវតែប្រជ្រៀតគ្នាដើរជាមួយប្រជាជនផ្សេងទៀត។ ហើយនៅពេលនោះ គ្រប់គ្នាបានធ្វើដំណើរតាមផ្លូវតែមួយ។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា នៅពេលដែលគាត់បានចេញពីផ្ទះឪពុកមាររបស់គាត់ គាត់បានសង្កេតឃើញថាមានសញ្ញាកំណត់ទិសដៅឲ្យមនុស្សដើរតាមផ្លូវដែលបានចង្អុលបង្ហាញនោះ។ លើសពីនេះទៀត ទាហានខ្មែរក្រហមដែលមានអាវុធនៅនឹងដៃ បាននាំគ្នាឈរតាមដងផ្លូវចម្ងាយប្រហែល១០ម៉ែត្រពីគ្នា។ ថ្វីបើកាំភ្លើងពួកគេភ្ជង់នឹងដីពិតមែន តែគេ

ស្រែកដាក់ប្រជាជនឲ្យដើរឲ្យលឿនៗ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានឃើញបុរសម្នាក់ដើរបញ្ច្រាសទិស និងបានអង្វរខ្មែរក្រហមសុំត្រឡប់ក្រោយដើម្បីទៅរកកូន។ ទាហានម្នាក់បានស្រែកគំហុកដាក់គាត់ឲ្យដើរទៅមុខវិញ បើមិនអីចឹងទេ គេនឹងបាញ់គាត់ចោល។ បុរសម្នាក់នោះ បានលុតជង្គង់សុំអង្វរថែមទៀត តែទាហានខ្មែរក្រហមបានវាយខ្នងគាត់នឹងកាំភ្លើង។

ដោយសារតែជឿជាក់ថា ពួកគេនឹងចាកចេញពីផ្ទះត្រឹមតែបីថ្ងៃ គ្រួសាររបស់លោក **គឹម វណ្ណី** មិនបានយកអីវ៉ាន់ប្រើប្រាស់សំខាន់ៗទៅជាមួយទេ។ ពួកគេត្រូវតែខ្ចីឆ្នាំងពីអ្នកធ្វើដំណើរផ្សេងទៀតដើម្បីដាំទឹកឆុងមី ហើយមីទៀតសោត គឺមានសម្រាប់តែបីថ្ងៃប៉ុណ្ណោះ រីឯនៅពេលយប់វិញ ពួកគេបានកាច់មែកឈើដើម្បីធ្វើជាកម្រាលក្រាលសម្រាក។ ក្រោយពីបីយប់មក ក៏នៅតែមិនឃើញមាននណាម្នាក់ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅទីក្រុងវិញដែរ។ ពួកគេត្រូវបានណែនាំពីសំណាក់ខ្មែរក្រហម ឲ្យរៀបចំបន្តដំណើរទៅកាន់ស្រុកកំណើតរៀងៗខ្លួនវិញ។ បន្ទាប់ពីការធ្វើដំណើរដោយថ្មើរជើងបានមួយរយៈមក ក្រុមគ្រួសាររបស់លោក **គឹម វណ្ណី** បានទៅដល់ស្រុកបាធាយ ខេត្តកំពង់ចាម និងបានស្នាក់នៅទីនោះពីរសប្ដាហ៍។

ពួកគេអាចបន្តជីវិតទៅបាន ដោយសារតែធ្វើការដោះដូរសំលៀកបំពាក់ល្អៗខ្លះដើម្បីយកបាយហូប។ ក្នុងទីតាំងនេះ លោក **គឹម វណ្ណី** បានកត់សម្គាល់ថា ប្រជាជនពីទីក្រុងភ្នំពេញត្រូវបានហៅថាជា “ប្រជាជន ១៧មេសា” រីឯប្រជាជនមូលដ្ឋានត្រូវបានហៅថាជា “ប្រជាជន ១៨មេសា”។

### *គ.៣. ខេត្តកំពត*

ដើមបណ្ដឹងរដ្ឋប្បវេណី និងក្រុមគ្រួសាររបស់គាត់ មិនបានស្នាក់ក្នុងខេត្តកំពង់ចាមនោះទេ។ ពួកគេបានធ្វើដំណើរបន្តទៅកាន់ខេត្តកំពត។ បើទោះណាជាឪពុកម្ដាយរបស់គាត់មានប្រភពចេញពីស្រុកអង្គរជ័យក៏ដោយ ពួកគាត់បែរជាត្រូវបានបញ្ជូនទៅកាន់ស្រុកប៉ាឡេល័យទៅវិញ។ នៅទីនោះ គេបានតម្រូវឲ្យសមាជិកក្នុងគ្រួសារគាត់ក្នុងម្នាក់ត្រូវរំឆ្ការដីឲ្យបាន១០ម៉ែត្រការេ ដើម្បីដូរយកអង្ករមួយកំប៉ុង។ បើទោះណាជា “ប្រជាជនថ្មី” និង “ប្រជាជនមូលដ្ឋាន” បានធ្វើការងារទំហំដូចគ្នាក៏ពិតមែន តែការទទួលបានរបបអាហារ គឺមិនដូចគ្នាទេ។ រាល់ប្រជាជនមូលដ្ឋានណាដែលបានធ្វើការ ត្រូវបានទទួលរបបអង្ករមួយកំប៉ុងក្នុងម្នាក់ៗ រីឯសមាជិកក្រុមគ្រួសារទាំងមូលរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អាចទទួលបានត្រឹមតែមួយកំប៉ុងប៉ុណ្ណោះ។ ប្រជាជនមួយចំនួនបានបង្ខំចិត្តលួចម្ហូបអាហារ ដើម្បីបំពេញក្រពះរួមមានដូចជា ផ្លែឈើ និងដើមរុក្ខជាតិផ្សេងៗដែលអាចទទួលទានបាន ដោយសារតែរបបដែលទទួលបានមិនគ្រប់គ្រាន់។ យោងតាមលោក **គឹម វណ្ណី** គ្រប់ៗគ្នាត្រូវបានគេប្រាប់ថា អង្គការត្រូវការឲ្យអ្នកគ្រប់គ្នាប្រគល់នូវសម្ភារផ្ទាល់ខ្លួនទាំងអស់ដាក់ សម្រាប់ការប្រើប្រាស់រួម ហើយគ្រប់គ្នាក៏ត្រូវតែបរិភោគអាហាររួមផងដែរ។

ដើមបណ្ដឹងរដ្ឋប្បវេណីបានប្រាប់តុលាការថា ក្រៅពីការស្លាប់ដោយសារខ្វះចំណីអាហារ និងខ្វះថ្នាំសង្កូវ ប្រជាជនខ្លះត្រូវបានចាប់ខ្លួន និងកំទេចចោល។ យោងតាមលោក **គឹម វណ្ណី** កងឈ្លបខ្មែរក្រហមបានស្រាវជ្រាវ និងតាមដាននូវរាល់សកម្មភាពទាំងអស់របស់ប្រជាជន១៧មេសា។ គាត់បានរម្លឹកឡើងវិញថា ប្រធានសហករណ៍ បានបញ្ចុះបញ្ចូលគាត់ឲ្យប្រាប់ពីប្រវត្តិសាវតាគ្រប់គ្នានៅក្នុងក្រុមគ្រួសារគាត់ ជាពិសេសប្រវត្តិរបស់ឪពុករបស់គាត់ ដោយបានសន្យាថា នឹងឲ្យទទួលទាន បើគាត់ផ្ដល់ព័ត៌មានឲ្យនោះ។ ប៉ុន្តែគាត់នៅតែឆ្លើយតបជាដដែលៗថា ឪពុកគាត់ គឺជាអ្នករត់រម៉ក បើទោះបីជាគាត់បានដឹងថា ឪពុករបស់គាត់ គឺជាវរ

សេនីឯកក្នុងកងទ័ពជើងទឹក មុនឆ្នាំ១៩៧៥ ក៏ដោយ។ លោក **គឹម វណ្ណី** ត្រូវបានចោទថាជា "កូនប្រុសរបស់ជនក្បត់" នៅពេលដែលក្រោយមកទៀត ពួកខ្មែរក្រហមបានរកឃើញរូបថតឪពុករបស់គាត់ស្លៀកពាក់ឯកសណ្ឋានទាហានជើងទឹកឈរថតនៅលើកប៉ាល់។ គេបានដាក់ច្រវ៉ាក់កជើងគាត់ និងបានវាយដំគាត់ពេញមួយសប្តាហ៍។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏បានរម្លឹកផងដែរពីការចាប់ខ្លួនឪពុករបស់គាត់។ ទាហានខ្មែរក្រហមបានចងដៃទាំងពីររបស់ឪពុកគាត់ទៅក្រោយ ហើយពួកគេបានវាយក្បាលឪពុកគាត់ និងបានសើចនៅពេលដែលមានឈាមហូរចេញមក។ លោក **គឹម វណ្ណី** បាននិយាយថា "ខ្ញុំមានញញួរនៅនឹងដៃ ហើយដៃម្ខាងទៀតខ្ញុំកាន់ខ្សែគោ តែខ្ញុំមិនអាចធ្វើអីកើត...ខ្ញុំនិយាយអីក៏មិនចេញ ស្រក់តែទឹកភ្នែក"។[16] គាត់បានរម្លឹកឡើងវិញថា ឪពុកគាត់បាននិយាយទៅកាន់គាត់ថា "ថែរក្សាខ្លួនឲ្យបានល្អ កូនប្រុស!"[17]។

ប្អូនបង្កើតរបស់លោក **គឹម វណ្ណី** ម្នាក់បានស្លាប់ព្រោះតែធ្វើការហួសកម្លាំង។ គាត់បានផ្តល់សក្ខីកម្មថា អ្នកស្លាប់ក្នុងអំឡុងរបបនេះគួរឲ្យ "អាណោចអាធ័មណាស់" ព្រោះមិនមានការរៀបចំធ្វើបុណ្យទាន តាមផ្លូវសាសនាត្រឹមត្រូវទេ។ ហើយជំនួសមកវិញមក នៅពេលមានមនុស្សស្លាប់ សពអ្នកទាំងនោះបានត្រឹមតែគ្របនឹងស្លឹកឈើ ឬយកទៅកប់ចោលតែប៉ុណ្ណោះ។ គាត់និយាយថា "អ្នកស្លាប់ក្នុងរបបនោះ គឺស្លាប់ដូចខ្មោចសត្វ" ដូច្នោះដែរ។[18]

### ឥ.៤. ការបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់

ប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៨ ប្រជាជន១៧មេសា ដែលនៅសេសសល់ត្រូវបានបញ្ជូនទៅកាន់សហករណ៍ខេត្តពោធិ៍សាត់។ ស្ថានភាពរស់នៅទីនោះ គឺមិនមានភាពខុសប្លែកគ្នាពីសហករណ៍ចាស់នៅខេត្តកំពតទេះ គ្រប់គ្នាត្រូវតែធ្វើការងារធ្ងន់ៗ និងបានទទួលរបបអាហារមួយពេលៗត្រឹមតែបបររាវៗតែប៉ុណ្ណោះ។

### ឥ.៥. សេចក្តីថ្លែងការណ៍ពីទុក្ខសោក អត្តចរិត និងភាពជឿជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី

លោក **គឹម វណ្ណី** បានឆ្លើយតបយ៉ាងរួសរាន់នូវរាល់សំណួរដែលបានសួរ យោងតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់។ ទោះជាយ៉ាងណា គាត់ហាក់ដូចជាមិនមានភាពប្រាកដប្រជាក្នុងការផ្តល់នូវទីតាំងភូមិសាស្ត្រលម្អិត ដូចជាឈ្មោះទីតាំងមួយចំនួនដែលគាត់បានឆ្លងកាត់បន្ទាប់ពីចាកចេញពីទីក្រុងភ្នំពេញ។ គាត់បានពន្យល់ថា គាត់នៅក្មេងពេកទាំងក្នុងដំណាក់កាលជម្លៀសចេញពីទីក្រុង និងពេលក្រោយៗជាបន្ត បន្ទាប់ទៀតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោក **គឹម វណ្ណី** បានស្តែងចេញនូវសេចក្តីរន្ធត់ចិត្តរបស់ខ្លួន និងបានយំនៅពេលដែលគាត់ព្យាយាមរម្លឹកឡើងវិញនូវស្ថានភាពកម្សត់វេទនានានា ក៏ដូចជាបទពិសោធន៍នៃការធ្វើទុក្ខបុកម្នេញដែលគ្រួសារគាត់បានទទួល ជាពិសេស នៅពេលដែលគាត់និយាយពីរឿងរ៉ាវដែលបានកើតឡើងទៅលើឪពុករបស់គាត់។

នៅក្នុងសេចក្តីថ្លែងការណ៍ពីទុក្ខសោក លោក **គឹម វណ្ណី** បានរម្លឹកសាឡើងវិញនូវបទពិសោធន៍ដែលក្រុមគ្រួសារគាត់បានទទួលរង ដោយបាននិយាយថា ពួកគេត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែង ចោល

ទ្រព្យសម្បត្តិ និងខានបានរៀនសូត្រ នៅឯសហករណ៍ឯណោះវិញ ពួកគេត្រូវបានរៀបចំឲ្យទៅធ្វើការងារធ្ងន់ៗដែលនាំឲ្យខ្សោះអស់កម្លាំង ហើយថែមទាំងត្រូវបានបង្អត់អាហារមិនឲ្យទទួលទានគ្រប់គ្រាន់ថែមទៀតផង។ លោក **គីម វណ្ណី** បានថ្លែងថា ប្អូនស្រីរបស់លោក និងសាច់ញាតិរបស់គាត់ជាច្រើនរូបទៀតបានស្លាប់ដោយសារភាពអត់ឃ្លាន។ គាត់បាននិយាយថា ស្ថានភាពរបស់គ្រួសារគាត់ ក៏ដូចជាស្ថានភាពរបស់ប្រជាជនដទៃទៀតនៅជុំវិញប្រទេសដែរ ខ្មែរក្រហមត្រូវទទួលខុសត្រូវនូវទុក្ខលំបាកវេទនាទាំងនេះ។ គាត់បានបន្ថែមថា "ពួកវាបានសម្លាប់ឪពុកខ្ញុំ សម្លាប់ឪពុកធំ និងម្តាយមីង ព្រមទាំងសាច់ញាតិជាច្រើនទៀតយ៉ាងអយុត្តិធម៌បំផុត"។[19] គាត់បានធ្វើការបញ្ជាក់ថា៖ "រាល់លើកដែលខ្ញុំនឹកឃើញនូវអ្វីដែលបានកើតឡើង វាហាក់ដូចជានៅថ្មីៗ នៅនឹងភ្នែកខ្ញុំ ហើយធ្វើឲ្យខ្ញុំខឹងស្ទើរទប់កំហឹងមិនបាន"[20] ដូច្នេះហើយបានជាគាត់ចូលរួមធ្វើជាទាហានព្រោះតែគាត់ចង់សងសឹក។ ទោះជាយ៉ាងណា គាត់មិនបានទទួលជោគជ័យក្នុងការសងសឹកទេ ហើយសព្វថ្ងៃគាត់បានក្លាយខ្លួនជាកម្មករលក់កម្លាំងមួយរូប។ គាត់បានជម្រុញឲ្យតុលាការស្វែងរកយុត្តិធម៌ដល់រូបគាត់ និងដាក់ទោសទណ្ឌដល់បុគ្គលទទួលខុសត្រូវ "ក្នុងកម្រិតធ្ងន់បំផុត" ដើម្បីឲ្យសមនឹងការបាត់បង់ដែលគាត់បានទទួល ក៏ដូចជាឲ្យសមនឹងទុក្ខវេទនាដែលប្រជាជនកម្ពុជាទាំងអស់បានទទួលរងពីរបបនេះ។

## ឃ. ការផ្តល់សក្ខីកម្មរបស់លោក ហ៊ុន ឈុនលី

សាក្សី **ហ៊ុន ឈុនលី** (TCW-247) បានផ្តល់នូវសក្ខីកម្មពីព្រឹកថ្ងៃព្រហស្បតិ៍ រហូតដល់ថ្ងៃសុក្រ។[21] សាក្សីរូបនេះ ធ្លាប់ជាគ្រូពេទ្យព្យាបាលតាំងពីមុន និងក្នុងអំឡុងពេលខ្លះៗនៃរបបខ្មែរក្រហម។ ក្នុងឆ្នាំ១៩៦៧ គាត់ត្រូវបានទទួលការតែងតាំងឲ្យទៅធ្វើការនៅមន្ទីរពេទ្យស៊ីវិលនៃខេត្តបាត់ដំបង។ កាលពីឆ្នាំ១៩៧៣ គាត់បានចូលរួមក្នុងជួរកងទ័ព និងក្រោយមកទៀតគាត់បានចូលធ្វើការក្នុងមន្ទីរពេទ្យ៤០៣ ដែលជាមន្ទីរពេទ្យទាហាន។ គាត់បានរស់នៅក្នុងខេត្តបាត់ដំបង ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបន្តរស់នៅរហូតដល់ឆ្នាំ១៩៩២ មុនពេលប្តូរទៅរស់នៅទីក្រុងភ្នំពេញ។

ការសួរដេញដោលលើរូបគាត់បានផ្តោតសំខាន់ទៅលើបទពិសោធន៍ទាំងឡាយ ដែលបានឆ្លងកាត់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ បូករួមទាំងការកម្ទេចបុគ្គលិកពេទ្យពីរបប **លន់ នល់** និងស្ថានភាពទូទៅក្នុងមន្ទីរពេទ្យ។ សាក្សីរូបនេះ ក៏ត្រូវបានសួរដេញដោលអំពីសៀវភៅដែលគាត់បានសរសេររៀបរាប់ពីជីវិតជាគ្រូពេទ្យម្នាក់ក្នុងអំឡុងពេលនោះ។ លោក **ហ៊ុន ឈុនលី** បានរក្សាទុកនូវកំណត់ហេតុប្រចាំថ្ងៃរបស់ខ្លួនក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែបានសម្រេចដុតចោល ដោយសារតែខ្មែរក្រហមបានស្រាវជ្រាវ និងរុះរើអីវ៉ាន់ក្នុងផ្ទះគាត់ជាច្រើនលើកច្រើនសា។ ដោយសារតែគ្មានកំណត់ហេតុប្រចាំថ្ងៃ គាត់ត្រូវតែសរសេរសៀវភៅផ្អែកលើការចងចាំដែលគាត់នៅមាន។ សៀវភៅរបស់គាត់ បានបោះពុម្ពលើកដំបូងក្នុងខែមករា ឆ្នាំ២០០៦[22] និងបានបោះពុម្ពលើកទីពីរបន្ទាប់ពីបានកែសម្រួលចុងក្រោយក្នុងឆ្នាំ២០១០។

### *ឃ.១. ការដាក់អាវុធរបស់ទាហាន លន់ នល់ ក្នុងឆ្នាំ១៩៧៥*

កាលពីខែមេសា ឆ្នាំ១៩៧៥ លោក **ហ៊ុន ឈុនលី** បានធ្វើការជាគ្រូពេទ្យម្នាក់ក្នុងមន្ទីរពេទ្យយោធានៃខេត្តបាត់ដំបង ឬហៅថាជាមន្ទីរពេទ្យ៤០៣។ នៅមន្ទីរពេទ្យ៤០៣ មានបុគ្គលិកពេទ្យប្រមាណជា៣០នាក់ និងទទួលព្យាបាលឲ្យតែទាហានរបស់ **លន់ នល់** តែប៉ុណ្ណោះ។ កាលពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រហែល

ជាម៉ោង៧ព្រឹក សាក្សីបានឮសេចក្ដីប្រកាសតាមវិទ្យុរបស់លោកឧត្ដមសេនីយ៍ **ម៉ី សុខចាន់** និងលោក **លន់ នល់** ប្អូនប្រុសបង្កើតរបស់លោក **លន់ នល់**។ សាក្សីបាននិយាយថាៈ

> *ខ្ញុំបានឮលោកឧត្ដមសេនីយ៍ទាំងពីរនេះនិយាយថា ពួកគេបានបរាជ័យ ហើយពួកគេព្រមទទួលការបរាជ័យនេះ។ ពួកគេទាំងពីរបានប្រកាសឲ្យទាហានរបស់សាធារណរដ្ឋទាំងអស់ នៅទូទាំងប្រទេសត្រូវនាំគ្នាដាក់អាវុធចុះ។*[23]

នៅវេលាប្រហែលជាម៉ោង៣រសៀល នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ លោក **ហ៊ុន ឈុនលី** បានចាប់ផ្ដើមឃើញទាហានខ្មែរក្រហមខ្លះបានចូលដល់សួនសាធារណៈមួយចំនួននៅខេត្តបាត់ដំបង។ នៅវេលាម៉ោង១ទៀបភ្លឺនៃព្រឹកថ្ងៃបន្ទាប់ គាត់បានឮសំឡេងបើកម៉ូតូ បូករួមនឹងសំឡេងហ៊ោកញ្ជៀវ "លាន់ឮកងរំពងជុំវិញក្រុងបាត់ដំបង"។ សាក្សីបាននិយាយថា ខ្មែរក្រហមបានដាស់ប្រជាជនឲ្យក្រោក "ដើម្បីចូលយកម៉ូតូជិះហែហមក្បួនតាមដងផ្លូវ និងឲ្យដើម្បីពួកគេអាចស្រែកអបអរ និងសូត្រពាក្យស្លោកផ្សេងៗ"។[24] ប្រជាជនខ្លះរួមទាំងអភិបាលខេត្តបាត់ដំបងបាននាំគ្នាភៀសខ្លួនទៅកាន់ប្រទេសថៃ។ ដោយឡែក សាក្សីបានជំទាស់មិនព្រមចេញ ដោយគាត់បាននិយាយថា "គាត់ចង់ធ្វើការជួយប្រទេសជាតិឲ្យចម្រុងចម្រើន និងស្អាតស្អំ"។[25]

យោងតាមលោក **ហ៊ុន ឈុនលី** ទាហានខ្មែរក្រហមបានបណ្ដើរប្រជាជនវៀតណាម ឲ្យឡើងទូកត្រឡប់ទៅកាន់ប្រទេសពួកគេវិញ ខណៈដែលកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ មានឡានត្រាក់ធំៗចំនួន៥ផ្សេងទៀត បានដឹកចេញទៅសុទ្ធតែជាអ្នកមានឋានន្ដរសក្ដិត្រឹមអនុសេនីយ៍ទោឡើងទៅ។ គាត់បានដឹងក្រោយមួយខែមក តាមរយៈអ្នកបើកបរឡានត្រាក់ម្នាក់ក្នុងចំណោមឡាន៥នោះថា ពួកគេទាំងនោះត្រូវបានដឹកទៅកាន់ភ្នំធិបតី (តាប្រេ) ទៅសម្លាប់។ សម្រាប់ទាហានដែលមានឋានន្ដរសក្ដិទាបជាងនេះ ត្រូវបានចាត់ឲ្យទៅធ្វើការងារកសិកម្ម។ សាក្សីបានរម្លឹកឡើងវិញថា ព្រះសង្ឃត្រូវបានស្នើឲ្យចេញពីវត្តក្នុងឆ្នាំ១៩៧៦ រីឯវិហារកាតូលិកធំមួយនៅខេត្តបាត់ដំបងត្រូវបានកម្ទេចចោល។ បើទោះជាគាត់មិនបានឃើញដោយផ្ទាល់ភ្នែកខ្លួនឯងដោយផ្ទាល់ក៏ដោយ ក៏សាក្សីបានផ្ដល់សក្ខីកម្មថា គាត់បានឮថា គេបានសម្លាប់នាយកសង្ឃ។

### *ឃ.២. ការប្រព្រឹត្តិលើបុគ្គលិកពេទ្យ*

សាក្សីបាននិយាយថា កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកោះហៅបុគ្គលិកពេទ្យចំនួន១៣នាក់ពីមន្ទីរពេទ្យឲ្យឡើងជិះរថយន្ដ ដើម្បីទៅទទួលក្រុមពេទ្យបដិវត្តន៍ ដែលបុគ្គលិកទាំងនេះមានឋានន្ដរសក្ដិត្រឹមវរសេនីយ៍ទោ។ ក៏ប៉ុន្ដែ បើកបានចម្ងាយប្រមាណជា១១គីឡូម៉ែត្រពីមន្ទីរពេទ្យ បុគ្គលិកពេទ្យទាំង១១នោះ ត្រូវបានគេបញ្ជាឲ្យចុះពីឡាន និងបាញ់សម្លាប់ចោល។ លោក **ហ៊ុន ឈុនលី** បានថ្លែងថា ជាសំណាងរបស់លោកនៅពេលនោះដែលគាត់មិនបាននៅមន្ទីរពេទ្យ នៅពេលដែលគេមកប្រមូលយកបុគ្គលិកពេទ្យពេលនោះ។ គាត់បានពន្យល់ថា មុនថ្ងៃកើតហេតុមួយថ្ងៃ គាត់ "ហាក់ដូចជាមានអារម្មណ៍ចម្លែកនៅមិនសុខ" និងតែងតែគិតទៅដល់កូនទាំងពីររបស់គាត់ (ប្រពន្ធរបស់គាត់នៅភ្នំពេញ) គាត់ក៏បានសុំចេញពីមន្ទីរពេទ្យទៅផ្ទះ។ សាក្សីបានរម្លឹកឡើងវិញពីការឃើញអ្នកជម្ងឺនាំគ្នាដើរចេញតេះតោះពីមន្ទីរពេទ្យ ដោយលោកបាននិយាយថា គាត់ជឿជាក់ថា អ្នកជម្ងឺទាំងនោះបានចាកចេញ ដោយសារតែការភ័យខ្លាចទាហានខ្មែរក្រហម។

ដោយឡែកនៅឯមន្ទីរពេទ្យស៊ីវិលវិញ សាក្សីបាននិយាយថា គាត់បានចូលរួមប្រជុំមួយ ដឹកនាំដោយប្រធានភូមិភាគ៤ ឈ្មោះ **ខែក ប៉ែន** ហៅ មិត្ត **ស៊ូ**[26] កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ នាយកគ្រប់គ្រងមន្ទីរពេទ្យ គឺលោកវេជ្ជបណ្ឌិត **យឹម គឹមសាន** ត្រូវបានបណ្តេញចេញ។ នាយកគ្រប់គ្រងថ្មីម្នាក់ត្រូវជ្រើសរើសក្នុងចំណោមអ្នកបោសសម្អាត និងអ្នកយាម ពីព្រោះពួកគេជាកម្មសិទ្ធរបស់វណ្ណៈកសិករ។ យោងតាមសាក្សីលោក **ខែក ប៉ែន** បាននិយាយថា បដិវត្តន៍បានមកពីវណ្ណៈកសិករ ហើយវណ្ណៈកសិករអាចធ្វើការដឹកនាំបានគ្រប់ផ្នែកទាំងអស់ បូករួមទាំងផ្នែកសុខាភិបាល។ លោក **ហ៊ិន ឈុនលី** បាននិយាយថា សម្រាប់បុគ្គលិកពេទ្យនៅតាមមន្ទីរពេទ្យស៊ីវិលមួយចំនួនទៀត ក៏ត្រូវបានយកទៅកម្ទេច កាលពីដើមឆ្នាំ១៩៧៧។ សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានឮពី **ខែក ប៉ែន** ថា អង្គការមិនចាំបាច់ត្រូវចំណាយពេល៧ឆ្នាំក្នុងការបណ្តុះបណ្តាលឲ្យក្លាយជាវេជ្ជបណ្ឌិតទេ "អង្គការចំណាយពេលត្រឹមតែ១អាទិត្យ ដើម្បីបណ្តុះបណ្តាលមនុស្សឲ្យក្លាយជាវេជ្ជបណ្ឌិត...ហើយវេជ្ជបណ្ឌិតដែលបានទទួលការបណ្តុះបណ្តាលប្រាំពីរថ្ងៃហើយ នឹងអាចចេញធ្វើការភ្លាមៗនៅទូទាំងប្រទេស"។"[27]

## *ឃ.៣. ការជម្លៀសចេញពីខេត្តបាត់ដំបង*

លោក **ហ៊ិន ឈុនលី** បាននិយាយថា មានពេលមួយនោះក្នុងអំឡុងខែសីហា ឆ្នាំ១៩៧៥ គាត់បានជួបជាមួយវេជ្ជបណ្ឌិតមួយចំនួន ហើយពួកគេបាននិយាយថា ខ្មែរក្រហមបានដឹកមនុស្សតាមរថភ្លើងពីទីក្រុងភ្នំពេញ និងបានដាក់ពួកគេចោលនៅខេត្តពោធិ៍សាត់ និងបាត់ដំបង។ ប្រជាជនខ្លះដែលបញ្ជូនមក បានមកស្នាក់នៅក្នុងភូមិដំរីស្លាប់ ជាទីតាំងដែលលោក **ហ៊ិន ឈុនលី** បានរស់នៅ។ អ្នកជម្លៀសទាំងនោះ ត្រូវបានអនុញ្ញាតឲ្យបោះទីតាំងស្នាក់នៅក្នុងដីទំនេររបស់ "ប្រជាជនមូលដ្ឋាន" ហើយពេលខ្លះ "ប្រជាជនមូលដ្ឋាន" បានរស់នៅរួមគ្នាជាមួយអ្នកជម្លៀសទាំងនោះផងដែរ។

នៅក្នុងអំឡុងនៃការជម្លៀស សហករណ៍ទាំងឡាយមិនទាន់ត្រូវបានបង្កើតនៅឡើយទេ ហើយអ្នកជម្លៀសទាំងអស់ត្រូវបានអនុញ្ញាតឲ្យយកម្ហូបអាហារតាមខ្លួនបាន។ នៅពេលចូលឆ្នាំខ្មែរ ក្នុងឆ្នាំ១៩៧៦ សហករណ៍ត្រូវបានរៀបចំឡើង ហើយប្រជាជនត្រូវបានស្នើឲ្យរស់នៅជាសមូហភាព (រួម)។ សាក្សីបាននិយាយថា "គ្មានទេការអត់ឃ្លាន" ក្នុងឆ្នាំ១៩៧៥ ប៉ុន្តែនៅចុងឆ្នាំ១៩៧៦ ប្រជាជនជាច្រើនត្រូវបានស្លាប់។ គាត់ក៏បាននិយាយផងដែរថា ពាក់កណ្តាលនៃជនជាតិភាគតិចចាមដែលបានស្នាក់នៅក្នុងភូមិត្រូវបានស្លាប់។ ចំណែកឯ ប្រជាជនចាមដែលឃើថ្កាត់វិញ របបអាហារត្រូវបានកាត់ផ្តាច់ ហើយពួកគេត្រូវ "បានបង្ខំ" ឲ្យបរិភោគសាច់ជ្រូក។ យោងតាមលោក **ហ៊ិន ឈុនលី** បើទោះជាខ្មែរក្រហមបាននិយាយថា គ្មានអង្ករក្នុងស្តុកក្តីក៏គាត់ និងអ្នកភូមិផ្សេងទៀត បានឃើញមានឡានធំៗ ជារឿយៗបានចូលមកដឹកយកអង្ករពីស្តុកក្នុងខេត្តបាត់ដំបង។

## *ឃ.៤. ជីវភាពរស់នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ*

សាក្សី **ហ៊ិន ឈុនលី** បាននិយាយថា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មានការរើសកម្លាំងយោធាចេញពីអ្នកស្រែចម្ការក្រីក្រ "អ្នកដែលអាចសម្លាប់មនុស្សដោយគ្មានញញើតដៃ"។[28] សាក្សីបានបន្ថែម

ថា "ក៏មានកងជីវពលសម្ងាត់" រួមមានក្រុមយុវជនក្មេងៗ ជាអ្នកចាំលួចចូលដេកក្រោមគ្រែ ដើម្បីស៊ើបយកការណ៍ពីអ្នកស្រុកនៅពេលយប់។

សាក្សីក៏បានលើកឡើងផងដែរថា នៅក្នុងភូមិ ប្រជាជនត្រូវបានបែងចែកដាច់ពីគ្នា ជា "ប្រជាជនចាស់" ឬ "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មី"។ សាក្សីបានបញ្ចេញយោបល់ផ្ទាល់ខ្លួនថា ខ្មែរក្រហមមានចេតនាធ្វើការបែងចែកក្រុមមនុស្សឲ្យទៅជាទម្រង់នៃការរើសអើង។ សាក្សីបាននិយាយថាៈ

> *ខ្ញុំជឿជាក់ថា ការបែងចែកប្រភេទប្រជាជន គឺជាប្រភេទនៃចេតនាឲ្យមានការរើសអើងដោយខ្មែរក្រហម...ប្រជាជនត្រូវគេបែងចែកចេញ ជាវណ្ណៈកសិករក្រីក្រ ជាវណ្ណៈ កសិករក្រីក្រកណ្ដាល និងវណ្ណៈកសិករក្រីក្របំផុត។ ចំណែកឯប្រជាជនថ្មីវិញ គេចាត់អ្នកទាំងនោះថាជា "ប្រជាជនថ្មី" និងចែកជាប្រភេទផ្សេងៗបន្តបន្ទាប់ទៀត...ខ្មែរក្រហមមិនចូលចិត្តពួកគេទាំងនោះទេ ជាពិសេស ចំពោះអ្នកដែលមានស្បែក ឬសម្បុរជ្រះ (ស)។ ខ្មែរក្រហមជឿថា អ្នកទាំងនេះ គឺជាអ្នកមិនដែលត្រូវពន្លឺថ្ងៃ។*[29]

យោងតាមលោក **ហ៊ុន ឈុនលី** ប្រជាជនទាំងអស់បានព្យាយាមធ្វើយ៉ាងណាឲ្យសម្លៀកបំពាក់ថ្មីរបស់ពួកគេមើលទៅដូចខោអាវចាស់ ដោយជ្រលក់សំលៀកបំពាក់ទាំងនោះក្នុងភក់ ឬជ្រលក់នឹងទឹកដែលបានពីដើមរុក្ខជាតិម៉្យាង (ដើមម៉ាក្លឿ) ធ្វើឲ្យឡើងពណ៌ខ្មៅ និងយកខោអាវទាំងនោះទៅដាក់ហាលថ្ងៃ។ ប្រជាជនមិនហ៊ានពាក់ស្បែកជើងថ្មីទេ ហើយក៏មិនមានស្រីៗណាហ៊ានតុបតែងខ្លួន ដោយលាបក្រែមម្សៅអីដែរ។ សាក្សីបាន "បោះចោល" វ៉ែនតាផ្ទាល់ខ្លួនរបស់គាត់ ពីព្រោះតែខ្មែរក្រហមមិនយល់ស្របឲ្យមានអ្នករៀនសូត្រចេះដឹង ដូច្នេះ មិនមានអ្នកណាម្នាក់ពាក់វ៉ែនតាទេ ដើម្បីចៀសវាងការមើលទៅហាក់ដូចជាខ្លួនឯងជាអ្នកចេះដឹង។

លោក **ហ៊ុន ឈុនលី** បាននិយាយថា នៅក្នុងភូមិមួយចំនួន ខ្មែរក្រហមបានជ្រើសរើសថ្នាក់ដឹកនាំមួយចំនួនតាមក្រុមនីមួយៗ ដើម្បីធ្វើការស្រាវជ្រាវរកប្រវត្តិរូបពីប្រជាជនក្នុងក្រុមរៀងៗខ្លួនរបស់ពួកគេ។ ព័ត៌មានដែលទាមទារឲ្យមានក្នុងប្រវត្តិរូបរួមមានដូចជា ឈ្មោះ មុខរបរ និងអាយុ។ សាក្សីបានផ្ដល់សក្ខីកម្មថា គាត់មិនបានប្រាប់ខ្មែរក្រហមថា គាត់ធ្លាប់ធ្វើការជាពេទ្យទាហាននោះទេ តែបានប្រាប់គេថា គាត់ធ្លាប់ជាពេទ្យព្យាបាលប្រជាជនស៊ីវិលនៅឯមន្ទីរពេទ្យខេត្តបាត់ដំបង។ គាត់មិនបានដឹងទេ ថាតើពួកគេនឹងធ្វើប្រវត្តិរូបទាំងនោះទៅណា តែគាត់គ្រាន់តែបានដឹងថា រាល់សមាជិកគ្រួសាររបស់គាត់ត្រូវធ្វើប្រវត្តិរូបរៀងៗខ្លួនទៅកាន់មេក្រុមរបស់ខ្លួន។

សាក្សីបានរម្លឹកឡើងវិញថា គ្រប់គ្នាបានចូលរួមប្រជុំនៅពេលយប់ ដែល "ការប្រជុំនោះ គឺនិយាយតែរឿងដដែលៗ ពីស្ថានភាពខ្មាំងសត្រូវផ្ទៃក្នុងប្រទេស និងសត្រូវខាងក្រៅប្រទេស"។[30] យោងតាមសាក្សីក្នុងពេលប្រជុំមួយនោះក្នុងខែឧសភា ឆ្នាំ១៩៧៥ លេខាធិការភូមិភាគសមមិត្ត **ខែក ប៉ែន** បាននិយាយថា អង្គការបានគ្រោងនឹង "ផ្លាស់ប្ដូរប្រទេស ឲ្យពោរពេញទៅដោយបំណែកភ្លឺស្រែចែកជារ៉ៃ ជាហិចតា យ៉ាងមានរបៀប មានពណ៌ស្រូវក្នុងស្រែប្រែប្រួលគ្រប់រដូវកាល (ជាឧទាហរណ៍ស្ដីពីការធ្វើស្រែជាបន្តមិនទុកដីទំនេរពេលគឺមានពណ៌ចម្រុះ បន្ទាប់ពីមានពណ៌បៃតង មានពណ៌មាសបានពីផលស្រូវទុំ) ដូច្នេះ នៅពេលមើល

មកពីលើ គេនឹងអាចឃើញវាលស្រែនីមួយៗនឹងមានទ្រង់ទ្រាយដូចប្អូនជ្រុងគ្រប់ទិសទីពេញផ្ទៃប្រទេស"។[31] លោក **ហ៊ុន ឈុនលី** ក៏បាននិយាយផងដែរថា គ្រប់គ្នាត្រូវបានស្នើឲ្យបោះបង់កម្មសិទ្ធិផ្ទាល់ខ្លួន។ ក្នុងកិច្ចប្រជុំមួយផ្សេងទៀត គាត់បានដឹងពីការដកចេញលោក **ហ៊ូ នឹម** ជារដ្ឋមន្ត្រីនៃក្រសួងព័ត៌មាន។ បើទោះជាសាក្សីមិនបានឃើញនូវការបាត់ខ្លួនកម្មាភិបាលនៃភូមិភាគពាយព្យក្តី គាត់បានផ្តល់សក្ខីកម្មថា គាត់បានឃើញកម្មាភិបាលមកពីភូមិភាពបស្ចឹមត្រូវបានផ្ទេរឲ្យមកឈរជើងជំនួសអ្នកចាស់។ លើសពីនេះ ក្នុងខែមិថុនា ឆ្នាំ ១៩៧៥ សាក្សី និងអ្នកភូមិផ្សេងទៀត បានឃើញពួកខ្មើយមួយចំនួន និងសាកសពមនុស្សស្លាប់អណ្តែតតាមបណ្តោយដងស្ទឹងសង្កែទៅកាន់បឹងទន្លេសាប។ លោក **ហ៊ុន ឈុនលី** បាននិយាយថា មិនមានអ្នកណាម្នាក់ហ៊ានសួរនាំថា មានអ្វីកើតឡើងចំពោះសាកសពទាំងនោះទេ ព្រោះក្នុងជំនាន់នោះ គ្រប់គ្នាមិនហ៊ានគិតពីរឿងអ្នកដទៃទេ គិតតែពីរឿងខ្លួនឯងតែប៉ុណ្ណោះ។

### *ឃ.៥. មន្ទីរពេទ្យព្រែកហ្លួង មន្ទីរពេទ្យប៉េ១ និងមន្ទីរពេទ្យ ប៉េ២*

ក្រោយការភ្ជួររាស់បានមួយខែ សាក្សីបានទទួលសំបុត្រពីសមមិត្ត **ខែក ប៉ែន** ចាត់ឲ្យគាត់ទៅធ្វើការនៅពេទ្យព្រែកហ្លួង ដែលជាមន្ទីរពេទ្យថ្នាក់ស្រុកមួយសម្រាប់ព្យាបាលប្រជាជនស៊ីវិល។ ក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៥ បន្ទាប់ពីបានធ្វើការនៅមន្ទីរពេទ្យព្រែកហ្លួងបានពីរខែ លោក **ហ៊ុន ឈុនលី** បានទទួលសំបុត្រពីបុគ្គលម្នាក់ឈ្មោះ កម្មាភិបាល **ហឿន** ស្នើគាត់ឲ្យទៅធ្វើការព្យាបាលកងទ័ពខ្មែរក្រហមនៅពេទ្យទាហាន ប៉េ-២។ មានមន្ទីរពេទ្យស៊ីវិលមួយទៀត ត្រូវបានស្គាល់ថាជា មន្ទីរពេទ្យប៉េ-១។ សាក្សីធ្វើការនៅពេទ្យយោធាបាន១៦ខែ ហើយគាត់ក៏ត្រូវបានផ្លាស់ទៅធ្វើការនៅមន្ទីរពេទ្យស៊ីវិលបានពីរខែ។ លោក **ហ៊ុន ឈុនលី** បាននិយាយថា គាត់គ្រាន់តែជាបុគ្គលិកពេទ្យធម្មតាម្នាក់ដែលជា "អ្នកទោស" របស់ខ្មែរក្រហមនៅក្នុងមន្ទីរពេទ្យ។ មន្ទីរពេទ្យទាំងពីរស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាល **ហឿន** ។ សាក្សីបានថ្លែងថា កាលពីដំបូងទីនេះរបប "មានថ្នាំសង្កូវសេសសល់ខ្លះៗ" នៅតាមមន្ទីរពេទ្យមួយចំនួន ដោយឡែកនៅកៀកឆ្នាំ១៩៧៦ ខ្មែរក្រហមបានទទួលថ្នាំប្រឆាំងនឹងជម្ងឺគ្រុនចាញ់ និងប្រភេទថ្នាំផ្សះពីប្រទេសចិន។ យោងតាមសាក្សី **ហ៊ុន ឈុនលី** សម្ភារផ្គត់ផ្គង់ និងឧបករណ៍ពេទ្យនៅមន្ទីរពេទ្យទាហាន គឺមានគ្រប់គ្រាន់ល្មម ដូចនេះ ការធ្វើការវះកាត់ទាំងឡាយគឺត្រូវធ្វើត្រឹមមន្ទីរពេទ្យស៊ីវិលនៅខេត្តបាត់ដំបង។

អ្នកជម្ងឺនៅមន្ទីរពេទ្យស៊ីវិល ត្រូវបានព្យាបាលរបៀបផ្សេងពីគ្នាពីអ្នកជម្ងឺនៅឯមន្ទីរពេទ្យយោធា។ អ្នកជម្ងឺនៅពេទ្យយោធាបានទទួលទានអាហារបីពេលក្នុងមួយថ្ងៃ នៅខណៈដែលនៅឯពេទ្យស៊ីវិល អ្នកជម្ងឺទទួលបានរបបអាហារតែពីរពេលក្នុងមួយថ្ងៃ។ ខ្មែរក្រហម បានដកហូតយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនពីអ្នក ជម្ងឺនៅពេលពួកគេស្លាប់។ លោក **ហ៊ុន ឈុនលី** បាននិយាយផងដែរថា មានការស្រាវជ្រាវរកខ្មាំងនៅក្នុងមន្ទីរពេទ្យស៊ីវិល។

សាក្សីក៏បានលើកឡើងផងដែរពីការវះកាត់ពិសោធន៍ផ្សេងៗ ដោយលោកប្រាប់ថា ការនេះបានកើតឡើងទាំងនៅមន្ទីរពេទ្យប៉េ-១ និង មន្ទីរពេទ្យប៉េ-២។ គាត់បានរម្លឹកឡើងវិញពីស្ត្រីម្នាក់មានជម្ងឺវិកលទាំងផ្លូវកាយ និងផ្លូវចិត្ត។ នាងត្រូវបានគេវាយដំ និងត្រូវបានដឹកទៅកាន់មន្ទីរពេទ្យ។ ស្ត្រីនោះត្រូវបានដាក់ក្នុងស្ពែងសែងបន្ទាប់ពីចាក់ថ្នាំស្ពឹកហើយ គេបានរុញចូលក្នុងឡាននឹងបើកចេញទៅ។ សាក្សីបាននិយាយថា "តាមការសន្និដ្ឋានរបស់ខ្ញុំ គឺថាស្ត្រីម្នាក់នោះត្រូវបានពួកវាយកទៅវះកាត់ធ្វើការពិសោធន៍ ហើយបើទោះជាខ្ញុំមិនបាន

ឃើញដោយផ្ទាល់ភ្នែកខ្ញុំពីការវះកាត់ពិសោធន៍នោះក្តី ក៏ប៉ុន្តែខ្ញុំបានឃើញអ្នកជម្ងឺជាស្ត្រីម្នាក់នោះ បានសន្លប់ដោយសារថ្នាំស្ពឹក និងឃើញគេយកចេញទៅ”។[32] មានពេលមួយទៀតនោះ ស្ត្រីវ័យកណ្តាលម្នាក់បានចូលទៅមន្ទីរពេទ្យ និងបានប្រាប់សាក្សីថា មានកម្មាភិបាលបានស្នើឲ្យនាងជួយរៀបចំថ្នាំមួយចំនួន ពីព្រោះនាងអាចនិយាយភាសាបារាំងបាន។ ពេទ្យទាហានជាស្ត្រីម្នាក់នោះ បាននាំយកស្ត្រីអ្នកជម្ងឺវ័យក្មេងនោះចេញទៅ។ ក្រោយមកទៀត មានទាហានខ្មែរក្រហមបួននាក់ផ្សេងទៀតនាំគ្នាមកសែងស្ត្រីដែលដេកស្ងៀមលែងកម្រើកលើគ្រែស្នែង និងរុញបញ្ចូលក្នុងឡាន ហើយក៏បើកចេញទៅ។ លោក **ហ៊ុន ឈុនលី** បាននិយាយថា “ខ្ញុំបានកត់សម្គាល់ភ្លាមៗថា ក្មេងស្រីម្នាក់នោះទើបតែត្រូវបានគេវះកាត់ធ្វើការពិសោធន៍”។[33] ប្រហែលជា១៥នាទីក្រោយមក អ្នកដឹកអ្នកជម្ងឺជាស្ត្រីវ័យក្មេងបានត្រឡប់មកវិញ ដើម្បីរកអ្នកជួយទាញឡាន ព្រោះឡានបានក្រឡាប់។ ខណៈដែលលោក **ហ៊ុន ឈុនលី** កំពុងផ្តល់ការព្យាបាលដល់នាយកមន្ទីរពេទ្យឈ្មោះ **ផុន** ទាហានខ្មែរក្រហមម្នាក់បានចូលមកសួរយោបល់ថា តើត្រូវយ៉ាងម៉េចចំពោះ “នាងខ្មាំងម្នាក់នោះ”។ **ផុន** បានប្រាប់ទៅយ៉ាងស្រួលថា ឲ្យកម្ទាត់នាងចោលទៅ។ យោងតាមសាក្សី ក្រោយមកទៀតក្នុងថ្ងៃដដែល បុគ្គលិកពេទ្យម្នាក់បាននិយាយថា ស្ត្រីវ័យក្មេងដែលរងនូវថ្នាំសណ្តំនៅឡើយនោះ ត្រូវបានគេយកទៅកប់ទាំងរស់។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៧៧ ប្រធានមន្ទីរពេទ្យបានចេញបញ្ជាឲ្យបុគ្គលិកពេទ្យទាំងអស់រៀបចំបោសសម្អាតពេទ្យ និងបិទបង្អួចទាំងអស់។ មិនមានអ្នកជម្ងឺ ឬបុគ្គលិកពេទ្យណាមួយត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យឡើយ។ លោក **ហ៊ុន ឈុនលី** បានរម្លឹកឡើងវិញថា វេលាម៉ោង១០ព្រឹក មានឡានដឹកគណៈប្រតិភូចិនមកបំពេញទស្សនកិច្ចនៅមន្ទីរពេទ្យ និងបានចំណាយពេលប្រមាណជាមួយម៉ោងនៅទីនោះ។ សាក្សីបាននិយាយថា នៅពេលរសៀលជ្រេរបន្តិច មានគេប្រាប់គាត់ថា អង្គការចង់ឲ្យពួកគាត់ត្រឡប់ទៅកាន់សហករណ៍វិញ។ ដូចនេះ គាត់ក៏បានត្រឡប់ទៅកាន់សហករណ៍កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៧ និងបានក្លាយជាកសិករធម្មតាវិញ។

លោក **ហ៊ុន ឈុនលី** បានផ្តល់សក្ខីកម្មថា លោកវេជ្ជបណ្ឌិត **យឹម គឹមសាន** ជាប្រធានមន្ទីរពេទ្យព្រែកហ្លួង និងវេជ្ជបណ្ឌិត **ពឹង គឹមស៊ា** ប្រធានពេទ្យនៅវត្តសោមន្ស ត្រូវបានបាត់ខ្លួនបន្ទាប់ពីចូលឆ្នាំខ្មែរហើយក្នុងឆ្នាំ១៩៧៧។ ក្នុងឆ្នាំ១៩៨០ លោក **ហ៊ុន ឈុនលី** បានឃើញរូបថតរបស់វេជ្ជបណ្ឌិត **យឹម គឹមសាន** នៅមន្ទីរសន្តិសុខទួលស្លែង។ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ **អាប់ឌុលឡាក់** បង្ហាញបញ្ជីឈ្មោះអ្នកទោស លោក **ហ៊ុន ឈុនលី** បានបញ្ជាក់អះអាងថា ឃើញមានបញ្ជីចូលសរសេរថា “**យឹម គឹមសាន** ពីភូមិភាគពាយព្យ ជាវេជ្ជបណ្ឌិត” សំដៅលើឈ្មោះបុគ្គលដែលលោកទើបតែបានលើកឡើងប្រាប់តុលាការ។ ជាងនេះទៀត សាក្សីក៏បាននិយាយផងដែរថា វេជ្ជបណ្ឌិត **ពឹង គឹមស៊ា** ដែលមានឈ្មោះចុះក្នុងបញ្ជីអ្នកទោសដែរនោះ ក៏ជាបុគ្គលម្នាក់ដែលគាត់បានស្គាល់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណែង វេជ្ជបណ្ឌិតផ្សេងៗទៀតក្នុងខេត្តបាត់ដំបង សាក្សីបានអះអាងថា ដូចដែលគាត់បានសរសេរក្នុងសៀវភៅរបស់គាត់អ៊ីចឹង គឺថាមានតែវេជ្ជបណ្ឌិតពីររូបតែប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតៈ រូបគាត់ផ្ទាល់ និងវេជ្ជបណ្ឌិត **អ៊ុន ស៊ី** ជាវេជ្ជបណ្ឌិតផ្នែកស៊ីវិល។ សាក្សីក៏បានបញ្ជាក់អះអាងផងដែរថា មានបុគ្គលិកពេទ្យប្រមាណជាង៣០នាក់ ពីមន្ទីរពេទ្យស៊ីវិលក្នុងខេត្តបាត់ដំបងនៅរស់រានមានជីវិត និងច្រើនជាងពាក់កណ្តាលនៃពួកគាត់ទាំងនេះជាស្ត្រីមេម៉ាយ។

### *ឃ.៦. ភាពស្និទ្ធស្នាលនឹងជនជាប់ចោទ*

សាក្សី បានរាយការណ៍ពីការដឹងស្គាល់ជាមួយនឹងជនជាប់ចោទពីសម័យខ្មែរក្រហម។

### *ឃ.៦.ក. ការដឹងស្គាល់ពីជនជាប់ចោទ ខៀវ សំផន*

យោងតាមសាក្សី **ហ៊ុន ឈុនលី** បើទោះជាលោកមិនមានទំនាក់ទំនងល្អ ឬក៏មានភាពជិតស្និទ្ធជាមួយជនជាប់ចោទ **ខៀវ សំផន** ក្តី ក៏គាត់បានដឹងដែរថា លោក **ខៀវ សំផន** ធ្លាប់ជាចាងហ្វាងកាសែត ឡុបសេវ៉ាទ័រ (*L'Observateur*)។ បន្ទាប់ពីចូលឆ្នាំខ្មែរក្នុងឆ្នាំ១៩៧៦ សាក្សីបានរម្លឹកឡើងវិញថា បានស្តាប់ការផ្សាយវិទ្យុក្នុងឱកាសដែលអតីតព្រះមហាក្សត្រព្រះបាទ **នរោត្តម សីហនុ** បានប្រកាសលាលែងចេញ ពីតួនាទីរបស់ព្រះអង្គជាប្រមុខរដ្ឋ។ ក្រោយមកទៀត ក៏មានការប្រកាសប្រាប់ថា លោក **ខៀវ សំផន** ត្រូវ បានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ។ បន្ទាប់ពីការប្រកាសភ្លាមៗនោះ លោក **ខៀវ សំផន** បានអានរដ្ឋធម្មនុញ្ញនូវមាត្រាពាក់ព័ន្ធនឹងសិទ្ធិក្នុងការជ្រើសរើសសាសនាដែលខ្លួនចង់បាន និងសិទ្ធិស្មើភាពគ្នាក្នុងការទទួលបាននូវឱកាសការងារ។ សាក្សីបានសង្កត់ធ្ងន់ថា គាត់មានការគោរពចំពោះលោក **ខៀវ សំផន** ជាខ្លាំង តែគាត់បានថ្លែងថា គាត់មានការអន់ចិត្តចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងពេលក្រោយៗមកទៀត ដោយសាក្សីបាននិយាយថា៖

> *អង្កាល់នោះ មានប្រជាជនកម្ពុជាខ្លះ ជាពិសេសយុវជន មានការជឿជាក់ខ្លាំងណាស់ចំពោះលោក **ខៀវ សំផន** - **ហ៊ូ នឹម** និង **ហ៊ូ យន់** ដោយសារតែយើងចាត់ទុកថា អ្នកទាំងបីនេះជាបុគ្គលស្អាតស្អំ។ ខ្ញុំមិនជឿ ទោះជាម្តាយខ្ញុំនិយាយយ៉ាងម៉េចក៏ដោយ អ៊ីចឹងហើយបានជាក្រោយៗមកទៀត ខ្ញុំមានការអន់ចិត្តយ៉ាងខ្លាំងចំពោះអ្វីដែលបានកើតឡើងកន្លងមក។*[34]

### *ឃ.៦.ខ. គ្រួសាររបស់ជនជាប់ចោទ នួន ជា*

សាក្សីបាននិយាយថា គាត់បានស្គាល់ក្រុមគ្រួសាររបស់លោក **នួន ជា** ច្បាស់នៅពេលពួកគេរស់នៅក្នុងឃុំវត្តគរ។ លោក **ហ៊ុន ឈុនលី** បានធ្វើការនៅក្នុងភូមិវត្តគរ ខេត្តបាត់ដំបង កាលពីឆ្នាំ១៩៦៧។ សាក្សីបានពិពណ៌នាអ្នកភូមិនេះ ថាជាអ្នកភូមិដែលមាន "កម្រិតជីវភាពធូរធារ" និងបាននិយាយថា មានទាំង បញ្ញាជន និងមន្ត្រីរាជការជាច្រើនមានប្រភពចេញពីវត្តគរ។ សាក្សីក៏បានចាត់ទុកក្រុមគ្រួសាររបស់ជនជាប់ចោទ **នួន ជា** ថា ជា "គ្រួសារថ្លៃថ្នូរ និងត្រឹមត្រូវ" ហើយគាត់ដឹងដោយសារគាត់ធ្លាប់ធ្វើការព្យាបាលជម្ងឺដល់គ្រួសារមួយនេះ។ ទោះជាយ៉ាងនេះក្តី គាត់ក៏បាននិយាយដែរថា "ខ្ញុំមិនដែលបានស្គាល់ ឬ មានទំនាក់ទំនងអីជាមួយលោក **នួន ជា** ទេ"។ សាក្សីបានរម្លឹកឡើងវិញថា ក្នុងរបបខ្មែរក្រហម ប្អូនបង្កើតម្នាក់របស់លោក **នួន ជា** "មិនត្រូវបានគេផ្លាស់ប្តូរទៅទីតាំងណាផ្សេងឡើយ"។ ផ្ទុយទៅវិញគាត់បាន ក្លាយទៅជាអ្នកបើកបររថយន្តឲ្យរបបនេះទៅវិញ។ យោងតាមសាក្សី គឺថាការទទួលបានរបបអាហារនៅភូមិវត្តគរមិនមានភាពប្រែប្រួលទេ ក៏ប៉ុន្តែទោះជាយ៉ាងណា អ៊ំប្រុសម្នាក់របស់លោក **នួន ជា** ឈ្មោះ **ស៊ីវ ហេង** ត្រូវបាន "នាំយកទៅ" កម្ទេច។

### ឃ.៦.គ. ការដឹងឮពីផនជាប់ចោទ អៀង សារី

យោងតាមសាក្សី នៅពេលដែលគាត់នៅធ្វើការក្នុងមន្ទីរប៉េ-២ ប្រធានពេទ្យពេលនោះ បានប្រកាសប្រាប់ថា ទីក្រុងទាំងមូលនឹងត្រូវបិទមួយថ្ងៃ។ នៅពេលរសៀល សាក្សីបានឃើញមានឡានម៉ាក Mercedes អមដំណើរដោយហ្វូងមនុស្សមួយក្រុមបើកតាមដងផ្លូវ។ បុគ្គលិកយោធាម្នាក់នៅឯមន្ទីរពេទ្យ បានប្រាប់លោក **ហ៊ុន ឈុនលី** ថា មានម្នាក់ក្នុងចំណោមក្បួនហែហម គឺជាលោក **អៀង សារី** ជាអ្នកធ្លាប់ពិនិត្យពិច័យកិច្ចការរបស់កសិករនៅវាលស្រែ។ សាក្សីបាននិយាយថា គាត់បានដឹងថាលោក **អៀង សារី** ធ្លាប់ជារដ្ឋមន្ត្រីក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ។

### ឃ.៧. ភាពជឿជាក់ និងអត្តចរិតរបស់សាក្សី

លោក **ហ៊ុន ឈុនលី** ជាទូទៅបានឆ្លើយតបនូវរាល់សំណួរដែលសួរទៅរូបគាត់ដោយគ្មានការស្ទាក់ស្ទើរឡើយ។ តែទោះជាយ៉ាងណា សក្ខីកម្មរបស់គាត់ត្រូវបានផ្តាច់ចង្វាក់ជាញឹកញាប់ពីសំណាក់ភាគីការពារក្តី ដោយពួកគេបានធ្វើការជំទាស់ដំណើររឿងនៃព្រឹត្តិការណ៍ ដែលសាក្សីមិនបានឃើញដោយផ្ទាល់ភ្នែកខ្លួនឯង រួមបញ្ចូលទាំងដំណើររឿងដែលគាត់បាននិយាយប្រាប់តុលាការថា មានឡានត្រាក់ធំៗចំនួនប្រាំពេញដោយទាហាន **លន់ នល់** ត្រូវបានគេយកទៅកម្ទេច រីឯស្រីៗវិញត្រូវបានគេដុតទាំងរស់នៅឈាបនដ្ឋាន (ឡដុតខ្មោច) ជាដើម។ល។។ ក្រុមការពារក្តីក៏បានជំទាស់ផងដែរពីការសន្មតស្មានៗរបស់សាក្សីស្តីពីការវះកាត់ពិសោធន៍លើរាងកាយមនុស្ស ដោយសារតែសាក្សីបានទទួលស្គាល់រួចមកហើយថា ខ្លួនមិនធ្លាប់បានឃើញសកម្មភាពនោះដោយផ្ទាល់ភ្នែក ហើយក៏មិនដែលបានចូលរួមក្នុងពេលធ្វើការវះកាត់ណាមួយដែរ។ ទាក់ទងនឹងការសរសេរសៀវភៅរបស់គាត់វិញ សាក្សីបាននិយាយថា គាត់មិនបានពឹងផ្អែកលើសំណៅ ឬសំណេរណាមួយទេ ក្រៅតែពីការចងចាំដែលគាត់មាន តែទោះបីជាយ៉ាងណា គាត់បានទទួលស្គាល់ថា គាត់បានអានសៀវភៅប្រវត្តិសាស្ត្ររបស់ខ្មែរក្រហមជាច្រើន។ លោក **ហ៊ុន ឈុនលី** បាននិយាយថា "សៀវភៅទាំងនោះមិនមានអ្វីពាក់ព័ន្ធជាមួយការសរសេររបស់ខ្ញុំទេ ហើយខ្ញុំក៏មិនបានទទួលរងឥទ្ធិពលអ្វីពីសៀវភៅទាំងនោះដែរ"។ ជាងនេះទៅទៀត សាក្សីក៏បាននិយាយផងដែរថា "វគ្គអប់រំនយោបាយដុះលាងខួរក្បាល" ជាមួយរៀតណាមដែលគាត់បានចូលរួមកាលពីឆ្នាំ១៩៧៩ ក៏មិនមានឥទ្ធិពលដល់ការសរសេរសៀវភៅរបស់គាត់ដែរ។ មិនមានសំណួរណាមួយបានសួរឲ្យសាក្សីឆ្លើយនោះទេ ទាក់ទងនឹងបរិបទ "វគ្គអប់រំនយោបាយដុសលាងខួរក្បាល" មួយនេះ ពីព្រោះសាក្សីបាននិយាយថា វគ្គនេះបានកើតឡើងក្រោយឆ្នាំ១៩៧៩ ថ្មីៗ។ មកទល់ត្រឹមនេះ ចៅក្រម **ស៊ីលវៀ ខាតវ៉ៃយច៍** បានចេញសេចក្តីសម្រេចថា បញ្ហាទាក់ទងនឹងវគ្គបណ្តុះបណ្តាលមួយនេះ មិនពាក់ព័ន្ធនឹងអង្គហេតុ ដែលអង្គជំនុំជម្រះកំពុងតែធ្វើសវនាការលើសំណុំរឿង០០២/០០១ ទេ។[35]

## ផ្នែកទី ៣៖ បញ្ហាផ្លូវច្បាប់ និងនីតិវិធី

បញ្ហានីតិវិធីដែលបានកើតឡើងផ្ទួនៗក្នុងសប្តាហ៍នេះ ទាក់ទងនឹងស្ថានភាពជម្ងឺរបស់ជនជាប់ចោទ **អៀង សារី** និងសមត្ថភាពសម្បទារបស់គាត់ក្នុងការតាមដានសវនាកាប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត តុលាការក៏បានប្រឈមមុខនឹងការជំទាស់ពីសំណាក់ភាគី ស្តីពីបញ្ហានៃការគ្រប់គ្រងបន្ទប់សវនាការ ព្រមទាំងរបៀបរបបដែលភាគីជំទាស់គួរតែត្រូវបានអនុញ្ញាតឲ្យធ្វើការសួរដេញដោល។

### ក. កាយសម្បទារបស់លោក អៀង សារី ក្នុងការជំនុំជម្រះ

កាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ជនជាប់ចោទ **អៀង សារី** បានដាក់ការកត់សម្គាល់មួយជូនដល់អង្គជំនុំជម្រះស្តីពីការដកលិខិតលះបង់សិទ្ធិក្នុងការមានវត្តមានក្នុងបន្ទប់សវនាការ។[36] បើយោងតាមកំណត់សម្គាល់ លោក **អៀង សារី** មានចេតនាក្នុងការចូលរួមតាមដានដោយផ្ទាល់ក្នុងបន្ទប់សវនាការ លើកលែងតែរូបលោក ត្រូវបានជ្រើសរើសឲ្យទៅតាមដានសវនាការ ដោយប្រយោលពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការ។ យ៉ាងណាក៏ដោយ ក្នុងពេលដែលទើបចាប់ផ្តើមសវនាការបានបន្តិចនៃថ្ងៃអង្គារនាសប្តាហ៍នេះ មានការជូនដំណឹងថា លោក **អៀង សារី** បានចូលរួមតាមដានសវនាការពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការ និងមិនអាចតាមដានដោយផ្ទាល់ដោយអង្គុយក្នុងបន្ទប់សវនាការនោះទេ។[37] ក្រៅពីធ្វើការគូសបញ្ជាក់យ៉ាងច្បាស់លាស់ថា កូនក្តីរបស់ខ្លួនមានចេតនាចង់មានវត្តមាននៅក្នុងបន្ទប់សវនាការ លោកមេធាវី **ម៉ៃខល កាណាវ៉ាស** ដែលជាមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** ក៏បានចង្អុលបង្ហាញផងដែរថា ផ្អែកទៅលើការស្ទាបស្ទង់ ឬការធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយជនជាប់ចោទ បូករួមទាំងការប្រឹក្សាយោបល់ជាមួយវេជ្ជបណ្ឌិតព្យាបាលលោក **អៀង សារី** នៅក្នុងបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការកាលពីមុនការចាប់ផ្តើមសវនាការថ្ងៃអង្គារនេះ[38] គឺឃើញថា លោក **អៀង សារី** មិនអាចផ្ចង់អារម្មណ៍បានល្អក្នុងការតាមដានទេ ដោយសារតែភាពទន់ខ្សោយនៃសុខភាពផ្លូវកាយរបស់គាត់។

មេធាវី **កាណាវ៉ាស** បានស្នើដល់អង្គជំនុំជម្រះនូវជម្រើសឆ្លាស់គ្នាបីយ៉ាង។ ទី១ មេធាវី **កាណាវ៉ាស** ស្នើថា តុលាកាមានអ្នកត្រួតពិនិត្យម្នាក់លើលោក **អៀង សារី** គ្រប់ពេលវេលា ដូច្នេះហើយគ្រប់គ្នា រួមទាំងមេធាវីរបស់គាត់ ទាំងសាធារណជន ក៏អាចមើលឃើញពីករណីយកិច្ចទាំងនោះដែរ។ មេធាវីបានបន្តថា៖

> *យើងមិនចង់មកចូលរួមក្នុងដំណើរការសវនាការ នៅពេលដែលកូនក្តីរបស់យើងនៅឯបន្ទប់ខាងក្រោម (បន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការ) នោះទេ ហើយគាត់អស់កម្លាំង គាត់សម្រានលក់ គាត់ភ្ញាក់ដឹងខ្លួនម្តងម្កាល (ភ្ញាក់ពាក់កណ្តាលទី) ហើយមិនត្រឹមតែប៉ុណ្ណឹងទេ ពួកយើងកំពុងតែនាំគ្នាធ្វើពុត...ធ្វើពើថា ជាការពិតដែលលោក **អៀង សារី** កំពុងតែតាមដានសវនាការ ហើយគាត់កំពុងតែចូលរួមក្នុងដំណើរការការពារខ្លួនបានត្រឹមត្រូវ។*[39]

សំណើទី២របស់មេធាវី **កាណាវ៉ាស** គឺជាសំណើជ្រើសដោយកូនក្តីរបស់គាត់ ស្តីពីការមានចេតនារបស់ខ្លួនដើម្បីតាមដានសវនាការផ្ទាល់ក្នុងបន្ទប់សវនាការ។ តែទោះជាយ៉ាងណា លោក **កាណាវ៉ាស** បានប្រឆាំងទាស់ទុកជាមុននូវជម្រើសនេះ ដោយនិយាយថា គាត់យល់ច្បាស់ណាស់ថា អង្គជំនុំជម្រះនឹងមិនចង់ឲ្យសាធារណជនមើលឃើញពីសភាពរបស់លោក **អៀង សារី** ទេ ឬក៏មានវត្តមាននៅទីនោះ ដើម្បីបានធ្វើ

កំណត់ត្រានៃសភាពពិតប្រាកដរបស់គាត់។ ប្រការនេះ ជាហេតុធ្វើឲ្យ មេធាវី **កាណាវ៉ាស** ស្នើថា សហការីរបស់គាត់ម្នាក់ គួរតែអាចថតវីដេអូនៅពេលកូនក្ដីរបស់ខ្លួនកំពុងតាមដានសវនាការពីបន្ទប់សោតទស្សន៍។[40] សរុបសេចក្ដីមក គោលបំណងរបស់លោកមេធាវី គឺធ្វើយ៉ាងណាឲ្យមាន "ការធ្វើឲ្យដូចគ្នា" ទាំងនៅក្នុងបន្ទប់សវនាការ និងបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការ ពោលគឺត្រូវមាន "កំណត់ត្រាពេញលេញ" អំពី ស្ថានភាពរបស់កូនក្ដីគាត់។ មេធាវី **កាណាវ៉ាស** បានអះអាងថា ក្នុងនាមគាត់ជាមេធាវីប្រឹក្សាក្ដីមួយរូប គឺត្រូវធ្វើយ៉ាងណាដើម្បីធានាឲ្យបានកូនក្ដីរបស់ខ្លួនទទួលបាននូវការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ លោកបានថ្លែងក្នុងន័យចំអកថា "ពួកយើងកំពុងនាំគ្នាធ្វើពើថាលោក **អៀង សារី** គឺកំពុងចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗជាមួយយើង។ នេះជាចម្រៀងល្ខោនផ្ដោះផ្ដងប្រស្នា"។[41] លោក **កាណាវ៉ាស** បានប្រកាសថា ក្នុងដំណាក់កាលចាំបាច់ណាមួយនោះ គឺថាក្រុមការពារក្ដីរបស់លោកបានរៀបចំខ្លួននឹងដើរចេញពីបន្ទប់សវនាការ ប្រសិនបើសិទ្ធិរបស់កូនក្ដីខ្លួនមិនបានទទួលសិទ្ធិពេញលក្ខណៈ និងមិនបានការពារយ៉ាងត្រឹមត្រូវនោះទេ ហើយប្រសិនបើតុលាការនៅតែមិនមានចេតនាក្នុងការធ្វើកំណត់ត្រាឲ្យបានពេញលេញមួយពីស្ថានភាពរបស់កូនក្ដីខ្លួន។

បន្ទាប់ពីបានផ្ដល់ឱកាសដល់ភាគីក្នុងការសម្ដែងមតិយោបល់ និងបន្ទាប់ពីបានចំណាយពេលអស់ ៤៥នាទីក្នុងការពិគ្រោះយោបល់គ្នា អង្គជំនុំជម្រះបានជំទាស់នឹងការស្នើសុំរបស់មេធាវី **កាណាវ៉ាស** ដែលចង់ឲ្យមានការថតវីដេអូទាំងនៅពេលជនជាប់ចោទតាមដានសវនាការពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការ ឬនៅពេលណាដែលគាត់ត្រូវបាននាំមកអង្គុយតាមដានសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ ចៅក្រម **ខាតវ៉ាយច៍** បានពន្យល់ថា ផលវិបាកនៃការអនុញ្ញាតឲ្យជនជាប់ចោទ **អៀង សារី** អង្គុយក្នុងបន្ទប់សវនាការអាចនឹងបន្តពន្យារពេលសវនាការ។ លោកស្រីចៅក្រម ក៏បានធ្វើការរម្លឹកដល់មេធាវី **កាណាវ៉ាស** ថា អង្គជំនុំជម្រះអាចចេញសេចក្ដីសម្រេចលើបញ្ហានេះ ដោយយោងទៅលើមតិយោបល់ និងភស្តុតាងដែលបានពីអ្នកជំនាញវិជ្ជាជីវៈផ្នែកវេជ្ជសាស្ត្រតែប៉ុណ្ណោះ។ ចៅក្រម **ខាតវ៉ាយច៍** បានសង្កត់ធ្ងន់ថា មានតែការសង្កេតផ្នែកវេជ្ជសាស្ត្រទេដែលជាតម្រូវការចាំបាច់ ហើយមិនមែនជាការសង្កេតពីសំណាក់ចៅក្រម ពីសំណាក់មេធាវីការពារក្ដី ឬពីសំណាក់សាធារណជនទេ។

មេធាវី **កាណាវ៉ាស** បានឆ្លើយតបថា សេចក្ដីសម្រេចដែលបានពីការពិគ្រោះយោបល់របស់អង្គ ជំនុំជម្រះ គឺចង់ទប់ស្កាត់ក្រុមការពារក្ដីមិនឲ្យធ្វើកំណត់ត្រា នឹងនាំឲ្យមានការដាក់នូវសំណើមួយទៅអង្គជំនុំជម្រះសាលាដំបូងនាពេលអនាគតឆាប់ៗខាងមុខនេះ ហើយបើចាំបាច់ សំណើនឹងត្រូវដាក់ជូនទៅតុលាការកំពូល។ លោកមេធាវីបានតវ៉ាថា វាគឺជា "ការខុសគ្នាយ៉ាងសម្បើម" រវាងការមានវេជ្ជបណ្ឌិតសង្កេតតាមដានសុខភាពរបស់លោក **អៀង សារី** និងការធានាឲ្យបានថា គាត់ពិតជាបានតាមដានសវនាការប្រាកដមែន។ ជាថ្មីម្ដងទៀត មេធាវី **កាណាវ៉ាស** បានស្នើថា ក្រុមការពារក្ដីគួរតែត្រូវបានអនុញ្ញាតឲ្យថតវីដេអូដោយបន្តធ្វើការធានាដល់អង្គជំនុំជម្រះសាលាដំបូងថា ការថតវីដេអូជនជាប់ចោទនឹងមិនមានការខាតបង់អ្វី ឬក៏ធ្វើឲ្យដំណើរការសវនាការយឺតយ៉ាវនោះឡើយ។ ទីបំផុត អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសមាជិកម្នាក់នៃក្រុមការពារក្ដីនៅក្នុងបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការ ដើម្បីតាមដានស្ថានភាពសុខភាពរបស់លោក **អៀង សារី**។

### *គ.១. បញ្ហាដែលកើតជាថ្មីម្តងទៀត*

ថ្វីបើ មានសេចក្តីសម្រេចពីអង្គជំនុំជម្រះរួចហើយក្តី កាលពីថ្ងៃអង្គារ ក៏ក្រុមមេធាវីការពារក្តីរបស់លោក **អៀង សារី** បានបន្តលើកឡើងនូវសេចក្តីបារម្ភពីស្ថានភាពរបស់កូនក្តីខ្លួនពេញមួយសប្តាហ៍។ នៅក្នុងឱកាសមួយនោះ បន្ទាប់ពីលោក **អាង ឧត្តម** ដែលជាមេធាវីជាតិការពារក្តីលោក **អៀង សារី** បានទាញចំណាប់អារម្មណ៍ទៅលើអង្គហេតុដែលថា កូនក្តីរបស់ខ្លួនបានសម្រានលក់មួយស្របក់ ក្នុងពេលសវនាការកំពុងតែដំណើរការ។ ចៅក្រម **ខាត់វ៉ាយថ៍** បានផ្តល់អនុសាសន៍ដល់មេធាវីប្រឹក្សាក្តី ឲ្យមានប្រធានគ្រប់គ្រងសំណុំរឿងឲ្យដាស់លោក **អៀង សារី** បើគាត់សម្រាន ដោយនិយាយថា៖

> *នេះមិនមែនជាការស្តែងឲ្យឃើញថា លោក **អៀង សារី** មានបញ្ហាផ្លូវចិត្តណាមួយទេដូច ដែលអ្នកជំនាញបានលើកឡើងយ៉ាងច្បាស់លាស់រួចមកហើយ ហើយលោក **អៀង សារី** ខ្លួនឯងក៏មិនដែលបានទាមទារថា ខ្លួនមានសមត្ថភាពផ្លូវចិត្តគ្រប់គ្រាន់ដែរ។ លើសពីនេះ ការដេកលក់ អាចជាការចង្អុលបង្ហាញយ៉ាងសាមញ្ញថា លោក **អៀង សារី** មិនចាប់ អារម្មណ៍លើការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។*

ដល់ចំណុចនេះ មេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** គឺលោក **អ៊ីយ៉ានូស្ស៊ី** បានជូនដំណឹងថា គាត់ចាត់ទុកការស្មានរបស់ចៅក្រម **ខាត់វ៉ាយថ៍** ថាជាការថ្លែងដ៏ចម្លែកបំផុត ត្រង់ចំណុចដែលថា លោក **អៀង សារី** ដេកលក់ដោយសារតែខ្វះការចាប់អារម្មណ៍។ គាត់បានចោទសួរអំពីថា តើសេចក្តីថ្លែងការណ៍របៀបនេះជា "សេចក្តីថ្លែងយោបល់ក្នុងនាមជាអ្នកគ្រប់គ្រងម្នាក់" ឬជាសេចក្តីថ្លែងដែលបានពីអ្នកជំនាញការ?។ លោកមេធាវីបានចាត់សេចក្តីសន្និដ្ឋានរបស់ចៅក្រម **ខាត់វ៉ាយថ៍** ថាជា "ការមិនសមរម្យទាល់តែសោះ" ដែលការពិតលោកស្រីមិនមែនទាំងជាវេជ្ជបណ្ឌិត ហើយក៏មិនមែនជាអ្នកជំនាញការផ្នែកវេជ្ជសាស្ត្រមួយរូបផងនោះ។ នៅថ្ងៃបន្ទាប់មកទៀត មេធាវី **អាង ឧត្តម** បានពន្យល់ថា ការដាស់លោក **អៀង សារី** ឲ្យភ្ញាក់ មិនមែនជាការទទួលខុសត្រូវរបស់ប្រធានគ្រប់គ្រងសំណុំរឿងទេ។ គាត់ក៏បានសង្កត់ធ្ងន់ដោយក្តីបារម្ភពីសកម្មភាពនៃការដាស់ជនជាប់ចោទឲ្យភ្ញាក់ អាចនឹងបង្កហេតុទៅជានាំឲ្យគាំងបេះដូងធ្ងន់ធ្ងរ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង មិនបានធ្វើការកែប្រែណាមួយពីសេចក្តីសម្រេចរបស់ខ្លួន ដែលបានចេញកាលពីថ្ងៃអង្គារនេះ។

ថ្វីបើមានសេចក្តីសម្រេចពីអង្គជំនុំជម្រះដែលថា អង្គជំនុំជម្រះ នឹងពិចារណាតែលើរបាយការណ៍ ធ្វើដោយគ្រូពេទ្យព្យាបាលក៏ដោយ ក៏ក្រុមមេធាវីការពារក្តីរបស់លោក **អៀង សារី** បានដាក់សំណើរសុំឲ្យអនុញ្ញាតប្រធានគ្រប់គ្រងសំណុំរឿងរបស់ខ្លួន អាចធ្វើការសង្កេតតាមដានជាប្រចាំថ្ងៃនូវស្ថានភាពសុខភាពរបស់កូនក្តីខ្លួនពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការ។[42] ក្រុមសហព្រះរាជអាជ្ញា បានធ្វើការប្រឆាំងផ្ទួនៗចំពោះការដាក់សំណើរកហេតុផលប្រចាំថ្ងៃដែលធ្វើដោយក្រុមការពារក្តីស្តីពីសម្បទារបស់ជនជាប់ចោទ **អៀង សារី** ក្នុងការតាមដានសវនាការ។ សំណើមួយ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ជូនដល់អង្គជំនុំជម្រះ[43] ក្រុមសហព្រះរាជអាជ្ញាបានបានទាមទារថា សំណើធ្វើដោយភាគីការពារក្តីបានយោងលើភាពមិនត្រឹមត្រូវ ស្តីពីច្បាប់ពាក់ព័ន្ធ ហើយបានធ្វើដោយមិនមានវត្តមាននៃការផ្លាស់ប្តូរត្រឹមត្រូវផ្នែកច្បាប់ ចំពោះកាលៈទេសៈជាមូលដ្ឋានផ្សេងៗ។ ដោយហេតុនេះ មានតែការសង្កេតពីអង្គភាពវេជ្ជសាស្ត្រប៉ុណ្ណោះ មានការពាក់ព័ន្ធនឹងគោលបំណងនៃការវិភាគសម្បទារបស់លោក **អៀង សារី** ហើយមិនមែនជាការសង្កេតរបស់ភាគីការពារក្តីពី

បន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការទេ។ នៅទីចុងបញ្ចប់ ភាគីសហព្រះរាជអាជ្ញាបានទទួលយកការដោះស្រាយជាមួយក្រុមមេធាវីការពារក្តី ដែលថាឲ្យមេធាវីការពារក្តីធ្វើកំណត់ត្រាបទសម្ភាសន៍រួមគ្នាជាមួយអង្គភាពវេជ្ជសាស្ត្រ។ ភាគីសហព្រះរាជអាជ្ញាបានថ្លែងថា វាមិនមែនជាតួនាទីរបស់មេធាវីការពារក្តីទេ ក្នុងការធ្វើការ "ស្របគ្នាស្មើនឹងការងារស៊ើបអង្កេត" ដោយស្វះស្វែងធ្វើកំណត់ត្រាបទសម្ភាសន៍ជាមួយបុគ្គលិកផ្នែកវេជ្ជសាស្ត្រ ដែលជាអ្នកមានតួនាទីរាយការណ៍ជូនអង្គជំនុំជម្រះ។ សហព្រះរាជអាជ្ញាព្រួយបារម្ភថាការធ្វើកំណត់ត្រាអាចជ្រៀតជ្រែកជាមួយសាក្សីសំខាន់ៗមួយចំនួន ដែលប្រការនេះមានតែបុគ្គលិកផ្នែកវេជ្ជសាស្ត្រទេ ដែលគួរតែត្រូវបានកោះហៅឲ្យមកផ្តល់ភស្តុតាងនៅមុខអង្គជំនុំជម្រះ។[44]

### *ក.២. ប្រសិទ្ធភាពនៃការចូលរួម*

យោងតាមមេធាវី **កាណាវ៉ាស** ការបង្ហាញខ្លួនទាំងក្នុងបន្ទប់សវនាការក្តី ឬពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការក្តី មិនមែនសុទ្ធតែផ្តល់គុណសម្បត្តិគ្រប់គ្រាន់ ក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពនោះទេ។ លោកមេធាវីបានតវ៉ាថា កូនក្តីរបស់គាត់ត្រូវតែដឹងខ្លួន និងអាចផ្ចង់អារម្មណ៍បានជាប្រចាំក្នុងការតាមដានសវនាការ មិនមែនសម្រាកលើគ្រែដេកលក់លីវៗ ដោយសារតែការមិនស្រួលខ្លួននោះឡើយ។[45] មេធាវីប្រឹក្សាក្តីលោក **អៀង សារី** ខ្លាចថា ដោយសារស្ថានភាពសុខភាពផ្លូវកាយកូនក្តីខ្លួន នឹងមិនអាចជួយក្នុងដំណើរការការពារក្តី ហើយក៏មិនអាចធ្វើការណែនាំអ្វីដល់មេធាវីប្រឹក្សាក្តីបានដែរ។ នៅក្នុងសំណើកាលពីថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១២ ដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ភាគីសហព្រះរាជអាជ្ញាបានអះអាងថា លោក **អៀង សារី** មានសម្បទាគ្រប់គ្រាន់ដើម្បីទទួលការជំនុំជម្រះ។ កំណត់សម្គាល់មួយនៅក្នុងយុត្តាធិការអន្តរជាតិ ស្តីពីសម្បទាក្នុងការទទួលការជំនុំជម្រះ គឺទាមទារថា ជនជាប់ចោទមានសិទ្ធិទទួលបានសមត្ថភាពដូចខាងក្រោមនេះ៖

(១) ការមានវិចារណញ្ញាណ ក៏ដូចជាការយល់ដឹងបានពីលក្ខណៈនៃបទចោទប្រកាន់ប្រឆាំងលើរូបគាត់

(២) ការមានវិចារណញ្ញាណ ក៏ដូចជាការយល់ដឹងអំពីគោលបំណងដំណើរការសវនាការប្រឆាំងលើរូបគាត់

(៣) សមត្ថភាពក្នុងការធ្វើបទបង្ហាញ ដើម្បីពិភាក្សាជាមួយមេធាវីការពារក្តីរបស់ខ្លួន និងសមត្ថភាព ក្នុងការជួយរៀបចំការពារខ្លួនជាមួយនឹងកម្រិតសមហេតុសមផលមួយនៃការយល់ដឹងរបស់ខ្លួន។[46]

ភាគីសហព្រះរាជអាជ្ញា បានទាញយកខ្លឹមសារពីការថ្លែងខាងលើនេះ គឺដើម្បីចង់សំដៅថា ជនជាប់ចោទមិនចាំបាច់ត្រូវការមាន "សមត្ថភាពយល់ដឹងពេញលេញ" នូវដំណើររឿងនៃសវនាការទេ ហើយក៏មិនត្រូវការឲ្យជនជាប់ចោទធ្វើប្រតិបត្តិការក្នុង "កម្រិតមុខងារខ្ពស់បំផុត" ដែរ។ ភាពគួរសមគឺថា ការធ្វើតេស្តរកឲ្យឃើញថា តើចុងចោទពេញចិត្តទេនឹងតម្រូវការអប្បបរិមាផ្សេងៗ ដែលបានចាត់ថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការធ្វើការជំនុំជម្រះឬអត់? លើសពីនេះ សហព្រះរាជអាជ្ញាបានកត់សម្គាល់លើការវាយតម្លៃសមត្ថភាពរបស់ជនជាប់ចោទក្នុងការប្រើប្រាស់សិទ្ធិរបស់គាត់ ដើម្បីទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌

ហើយវាក៏ជាការសមរម្យផងដែរ ក្នុងការពិចារណាថា ជនជាប់ចោទ គឺមានមេធាវីប្រឹក្សាជាតំណាង "ជាអ្នកដែលអាចចាត់ចែងជំនួសដោយពេញលេញ សម្រាប់ការខ្វះខាតនូវសមត្ថភាពពាក់ព័ន្ធណាមួយ"។[47] សំណើផ្សេងៗដែលបានដាក់ជូនដោយសហព្រះរាជអាជ្ញា និងភាគីការពារក្តី អាចចង្អុលបង្ហាញពីសេចក្តីត្រូវការមួយសម្រាប់អង្គជំនុំជម្រះ ដើម្បីធ្វើការបញ្ជាក់ ហើយដែលប្រហែលជាអាចនាំឲ្យមានការពិនិត្យសាឡើងវិញនូវស្តង់ដារក្នុងការមានសម្បទា ដើម្បីធ្វើការជំនុំជម្រះក្នុងបរិបទនៃសំណុំរឿង០០២ និងស្ថានភាពសុខភាពវេជ្ជសាស្រ្តរបស់ជនជាប់ចោទ **អៀង សារី**។

## ខ. តួនាទីរបស់មេធាវីប្រឹក្សា និងក្រមសីលធម៌វិជ្ជាជីវៈ

កាលពីសប្តាហ៍មុន បន្ទាប់ពីការច្រានចោលយ៉ាងដាច់អហង្ការពីសំណាក់អង្គជំនុំជម្រះចំពោះចេតនារបស់មេធាវីអន្តរជាតិ គឺកញ្ញា **អាន់តា ហ្គីស្សេ** ដែលមានបំណងចង់និយាយជួសមុខឲ្យកូនក្តីខ្លួន គឺលោក **ខៀវ សំផន**។ ចៅក្រម **និល ណុល** បានធ្វើការដោះស្រាយផ្ទាល់ជាមួយជនជាប់ចោទ**ខៀវ សំផន** ដោយបានសួរគាត់ថា តើជនជាប់ចោទ **ខៀវ សំផន** នៅតែរក្សាទុកនូវសិទ្ធិក្នុងការរក្សាភាពស្ងៀមស្ងាត់ចំពោះសំណួរដែលបានចោទសួរដោយដើមបណ្តឹងរដ្ឋប្បវេណី **ចៅ នី** ឬទេ?[48] សប្តាហ៍នេះ មេធាវី **អ៊ីយ៉ានូស្សុី** បានសម្តែងមតិចំពោះហេតុការណ៍នេះ និងបាននិយាយថា "នៅពេលដែលគាត់ និងសហការីការពារក្តីផ្សេងទៀត ធ្វើការដាក់សំណើ គឺពួកគេបានធ្វើក្នុងនាមកូនក្តីខ្លួន"។ លើសពីនេះ "មិនមានហេតុផលដាច់ខាត" ដែលប្រធានតុលាការធ្វើអន្តរាគមន៍ និង "ព្យាយាមបំបែកចេញពីគ្នារវាងមេធាវីប្រឹក្សាក្តី និងភាគីយ៉ាងដូច្នេះទេ"។ មេធាវី **អ៊ីយ៉ានូស្សុី** បានបន្តថា៖

> *ខ្ញុំសូមជំទាស់ដាច់អហង្ការនូវទង្វើ ដែលលោកប្រធានបានរារាំងមេធាវី **ហ្គីស្សេ** កាលពីសប្តាហ៍មុន ហើយខ្ញុំសូមសំណូមពរថា លោកប្រធានប្រហែលជាត្រូវផ្ទះបញ្ជាំងនូវទង្វើខ្លួនឯងឡើងវិញ ជាមួយនឹងក្រមសីលធម៌វិជ្ជាជីវៈជំនាញ ទាំងក្រមសីលធម៌ដែលមានចែងនៅ **អ.វ.ត.ក** និងក្រមសីលធម៌វិជ្ជាជីវៈនៃក្រុមព្រហ្មទណ្ឌកម្ពុជាដែលក្រុមទាំងនេះលោកអាចប្រើប្រាស់ ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់ថា យើងទាំងអស់គ្នានៅទីនេះ គឺកំពុងតែធ្វើការងារជាមេធាវីប្រឹក្សាឲ្យកូនក្តីរបស់ពួកយើង ហើយយើងនឹងកោតសរសើរបំផុត បើយើងទទួលបានការគោរពពីសំណាក់ លោក លោកស្រីជាចៅក្រម។*[49]

ប្រធានតុលាការអង្គជំនុំជម្រះ **និល ណុន** បានឆ្លើយតបចំពោះការធ្វើកំណត់សម្គាល់របស់មេធាវី **អ៊ីយ៉ានូស្សុី** ដោយបានទទួលស្គាល់ថា "ការលើកឡើងនេះ ជាមេរៀនមួយដល់អង្គចៅក្រម ដើម្បីធ្វើឲ្យការគ្រប់គ្រងដំណើរការនីតិវិធីសវនាការ កាន់តែមានភាពប្រសើរឡើងនាពេលអនាគតដ៏ខ្លីខាងមុខនេះ"។[50]

សំណើមួយនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ដាក់ជូនអង្គជំនុំជម្រះ[51] ក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** បានតវ៉ាថា ការអន្តរាគមន៍ពីសំណាក់ប្រធានតុលាការ គឺបានបង្ហាញនូវការរំលោភបំពាននូវសិទ្ធិរបស់កូនក្តីខ្លួនក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដោយបានពិពណ៌នាការឆ្លើយឆ្លងគ្នាដែល

បានធ្វើរវាងប្រធានតុលាការ និងជនជាប់ចោទ **ខៀវ សំផន** ក្នុងពេលនោះថា ជា "រឿងមិនគួរឲ្យចង់ជឿ និងចម្លែកអស្ចារ្យ" ។

ភាពទាក់ទងគ្នាក្នុងហេតុការដដែលនេះកាលពីសប្តាហ៍មុន មេធាវី **អ៊ីយ៉ានូស៊្បី** បានធ្វើការរម្លឹកថា ចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** ហាក់ដូចជាបានបើកឱកាសឲ្យមានការពិភាក្សាគ្នា ក្នុងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី **ចៅ នី** ដើម្បីឲ្យមេធាវី **ហ្គីស្សេ** សួរសំណួរ។ ទោះជាយ៉ាងនេះក្តី មេធាវី **អ៊ីយ៉ានូស៊្បី** បានបន្តថា បន្ទាប់ពីបានឮចៅក្រម **ខាតរ៉ាយថ៍** ខ្សិបដាក់ត្រចៀកលោកប្រធាន **និល ណុន** (ឮចូលក្នុងម៉ៃក្រូហ្វូន) ថា សំណើមិនគួរនឹងអនុញ្ញាត ទើបឲ្យធ្វើប្រធានតុលាការ ភ្លាមៗនោះបានបដិសេធតាមការណែនាំពីចៅក្រម **ខាតរ៉ាយថ៍** ដោយមិនបានធ្វើការ "ជជែកពិភាក្សាត្រឹមត្រូវ" ណាមួយ ជាមួយនឹងចៅក្រមផ្សេងទៀតឡើយ។ ចំណុចនេះ មេធាវី **អ៊ីយ៉ានូស៊្បី** បាននិយាយថា៖

> *តើយើងកំពុងតែបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ឬក៏យើងទាំងអស់គ្នានេះ កំពុងតែបង្ហាញខ្លួននៅចំពោះមុខតែបក្ខពួកក្រុមរបស់ចៅក្រម* ***ខាតរ៉ាយថ៍ -និល ណុន*** *? លោក លោកស្រីមានគ្នា៥នាក់ ដើម្បីផ្តល់នូវការសម្រេចលើបញ្ហាអ្វីមួយ។ យើងរំពឹងថា នឹងមានការជជែកពិភាក្សាទៅលើបញ្ហាទាំងអស់ ហើយយើងរំពឹងទុកថា គឺអង្គជំនុំជម្រះដែលចេញសេចក្តីសម្រេចផ្សេងៗ មិនមែនជាចៅក្រមឯកជនទេ។*[52]

ជាការឆ្លើយតប ប្រធានតុលាការបាននិយាយថា មានឧទាហរណ៍ខ្លះៗត្រូវបានកើតឡើងនៅពេលគាត់បានធ្វើសេចក្តីសម្រេចដោយការប្រុងប្រយ័ត្នផ្ទាល់ខ្លួនក្នុងនាមជាប្រធាននៃអង្គជំនុំជម្រះ ជាក់ស្តែងបញ្ហាទាក់ទងនឹងសេចក្តីប្រកាសឲ្យសម្រាក ឬចាប់ផ្តើមសវនាការ រីឯបញ្ហាផ្សេងៗទៀត បានកើតឡើងនៅពេលដែលក្រុមចៅក្រមនៃអង្គជំនុំជម្រះ ត្រូវរួមគ្នាចេញនូវសេចក្តីសម្រេចលើបញ្ហាអ្វីមួយ។ លោកប្រធានតុលាការបានបន្តថា៖

> *យើងបានព្យាយាមអស់ពីលទ្ធភាពធ្វើយ៉ាងណា ដើម្បីឲ្យដំណើរការសវនាការ និងការអនុវត្តន៍នីតិវិធីក្នុងតុលាការនេះ ក៏ដូចជាតាំងពីយើងនៅធ្វើការជាមួយតុលាការក្នុងស្រុក។ ខ្ញុំបានខិតខំប្រឹងប្រែងណាស់។ ជាការពិតណាស់ ដែលកំហុសអាចនឹងកើតមានឡើងនៅក្នុងពេលកំពុងអនុវត្តសេរីភាពនៃការសម្រេចមួយ ដែលអាចទុកចិត្តបាន ហើយវាប្រាកដណាស់ ដែលយើងបានខិតខំយ៉ាងខ្លាំង ក្នុងការធ្វើតាមនីតិវិធី និងជម្រើសដែលយើងមាន។*[53]

## គ. ការអនុវត្តន៍ការសួរដេញដោល និងស្តង់ដាររួម

ទាំងលោក **ហ្សាស្តី ប៉ៅ** ដែលជាមេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** និងលោក **កាណាវ៉ាស** ជាមេធាវីអន្តរជាតិការពារក្តីលោក **អៀង សារី** បានលើកយកបញ្ហានៃការស្នាក់ស្ទើររបស់សហព្រះរាជអាជ្ញាជាតិ **វេង ហ៊ត** ក្នុងការសួរសំណួរទៅកាន់សាក្សី **ហ៊ុន ឈុនលី** ឈរលើមូលដ្ឋាននៃចំណេះដឹងផ្ទាល់ខ្លួនដែលសាក្សីមាន ហើយដែលសហព្រះរាជអាជ្ញាមិនបានសុំឲ្យសាក្សីធ្វើការបញ្ជាក់ថា នណាជាអ្នកបានឃើញ ឬដឹងឮនូវព្រឹត្តិការណ៍មួយចំនួន ដូចដែលសាក្សីបានយោងកន្លងមក ជាពិសេសនៅពេលសាក្សីបានលើកឡើងនូវពាក្យ

“ពួកគេ” ឬ “គាត់”។ តើនណាជា “ពួកគេ” ឬជា “គាត់” ដែលជាអ្នកបានផ្ដល់នូវព័ត៌មានមួយចំនួនឲ្យសាក្សីបានយកមកនិយាយក្នុងតុលាការពេលនេះ។ លោក **ប៉ៅ** បានតវ៉ាថា ក្នុងនាមជាសាក្សី ត្រូវបានអនុញ្ញាតត្រឹមតែផ្ដល់សក្ខីកម្មតែលើអ្វីដែលពួកគាត់បានឮ និងបានឃើញដោយផ្ទាល់ភ្នែក ហើយនេះជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការត្រួតពិនិត្យរកនូវមូលដ្ឋានពិតនៃចំណេះដឹងដែលសាក្សីមាន។

ក្រមនីតិវិធីរដ្ឋប្បវេណី ផ្ដល់ការណែនាំឲ្យអនុលោមតាមការស៊ើបអង្កេតមួយ ដែលមានន័យថា ចៅក្រមទាំងឡាយ អាចដើរតួនាទីយ៉ាងសកម្មរបស់ខ្លួន ជាជាងការត្រួតត្រាមើលលំហូរនៃដំណើរការនីតិវិធី។ ទោះជាយ៉ាងនេះក្ដី មេធាវី **កាណាវាស** បានតវ៉ាថា អង្គជំនុំជម្រះក្នុងសំណុំរឿង០០២ បាន “ផ្ទេរនូវតួនាទីរបស់ខ្លួន” ទៅឲ្យព្រះរាជអាជ្ញាធ្វើការជំនួសតួនាទីខ្លួនជាចៅក្រមអង្គជំនុំជម្រះ។ បន្ទាប់ពីការសាកសួរដំបូងទីដោយប្រធានតុលាការពីប្រវត្តិរូបសង្ខេបត្រួសៗទៅកាន់សាក្សី អង្គជំនុំជម្រះកម្រនឹងសួរសំណួរលម្អិតទៅលើអង្គហេតុណាស់ តែបានប្រគល់ឱកាសក្នុងការសួរដេញដោលនេះ ទៅឲ្យភាគីជាអ្នកធ្វើ។ លោក **កាណាវាស** បាននិយាយថា៖

> *អ្វីដែលជាបញ្ហាដែលខ្ញុំបានរកឃើញគឺថា ភាគីការពារក្ដីមិនត្រូវបានអនុញ្ញាតឲ្យធ្វើការសួរអង្កេតយ៉ាងល្អិតល្អន់នោះទេ។ ដូច្នេះ ក្នុងន័យមួយទៀត អ្វីដែលយើងបានអនុវត្តតាមចេញពីប្រព័ន្ធច្បាប់ទាំងពីរ (ជាតិ និងអន្តរជាតិ) គឺជាការអនុវត្តន៍ដ៏អាក្រក់បំផុត។ លោក លោកស្រីចៅក្រមបានផ្ទេរកាតព្វកិច្ចមួយចំនួនរបស់ខ្លួនទៅឲ្យសហព្រះរាជអាជ្ញា ដែលជាបុគ្គលត្រូវបានសន្មត ឲ្យសួរនូវសំណួរទាំងឡាយណា ធ្វើម៉េចដើម្បីយកឲ្យបាននូវព័ត៌មានកៀកស្និទនឹងការពិត ហើយលោក លោកស្រី ចងដៃយើងទាំងពីរទៅក្រោយ (មិនអាចតបត) ពីព្រោះតឡូវហ្នឹង លោក លោកស្រីបានធ្វើវាឲ្យទៅជាបក្សមួយ ជាបក្សប្រឆាំងមួយហើយតឡូវនេះ លោក លោកស្រីនិយាយថា “អ្នកមិនអាចសួរសំណួរស៊ីជម្រៅបាន”។ ខ្ញុំមិនយល់ទាល់តែសោះ ថាតើវាជាការប៉ះទង្គិចគ្នានៃអរិយធម៌ ឬជាភាពខុសប្លែកគ្នានៃច្បាប់ជាប្រពៃណី ប៉ុន្តែខ្ញុំយល់ពីគោលការណ៍ច្បាប់ទាំងពីរ ហើយក៏បានធ្វើការលើច្បាប់ទាំងពីរនេះដែរ ហើយយើងបានអនុវត្តន៍តាមលំនាំច្បាប់ដ៏អាក្រក់បំផុត។*[54]

សហព្រះរាជអាជ្ញាអន្តរជាតិ **ថារិក អាប់ឌុលឡាក់** បានធ្វើការឆ្លើយតបដោយបានថ្លែងគាំទ្រនូវឥរិយាបថនៃការសួរដេញដោលរបស់សហការីជាតិខ្លួន គឺលោក **វេង ហ៊ត** និងបាននិយាយថា ប្រសិនជាក្រុមការពារក្ដីយកបញ្ហានៃការរៀបសំណួរដេញដោលរបស់ភាគីសហព្រះរាជអាជ្ញាមកជជែកនៅទីនេះ គឺមានន័យថា “ពួកគេក៏មានសមត្ថភាពយ៉ាងពិសេសក្នុងការលើកយកបញ្ហានេះក្នុងការសួរដេញដោលរបស់ពួកគេលើសាក្សី”។[55] លោក **អាប់ឌុលឡាក់** បានថ្លែងបន្តថា មិនថាទង្វើនេះ ជាការ “សួរដេញដោលស៊ីជម្រៅ” ឬជាការ “សួរដេញដោលសាមញ្ញ” នោះទេ វាជាការធ្វើតេស្ដរកភស្ដុតាងដ៏រឹងមាំ និងសំណួរដែលសមស្របណាស់នឹងសួរទៅគ្រប់សាក្សីទាំងអស់។

ប្រធានតុលាការ បានចេញសេចក្ដីសម្រេចប្រឆាំងនូវការជំទាស់ពីភាគីការពារក្ដី ទាក់ទងនឹងរបៀបនៃការសួរសំណួរ ដោយបាននិយាយថា “ចំពោះដំណាក់កាលនេះ អង្គជំនុំជម្រះនឹងមិនធ្វើការសួរដេញដោល

លើតម្លៃភស្តុតាងដែលបានពីការធ្វើតេស្តសាកល្បងចំពោះមុខយើងទេ”។[56] យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាគួរតែធ្វើយ៉ាងណាធានាឲ្យបានថា សំណួរទាំងឡាយដែលខ្លួនសួរគួរតែ “បានគ្រោងជាក់លាក់ ដើម្បីធានាថា សំណួរទាំងនោះ នាំឲ្យមានលទ្ធផលដល់ការស្វែងរកការពិត”។[57]

## ផ្នែកទី ៤៖ ការគ្រប់គ្រងសវនាការ

ជាលទ្ធផលមួយដ៏គួរឲ្យកត់សម្គាល់ ដោយសារសប្ដាហ៍នេះ អង្គជំនុំជម្រះបានស្ដាប់នូវសក្ខីកម្មពីសំណាក់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៣រូប និងសាក្សីមួយរូប។ ទោះជាយ៉ាងណា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ **អៀង សារី** និងបញ្ហាមួយចំនួនដែលសេសសល់ពីសប្ដាហ៍មុនមិនទាន់បានបញ្ចប់ បាននាំឲ្យកើតមានបញ្ហានៃការគ្រប់គ្រងសវនាការបន្តដល់សប្ដាហ៍នេះ។

### ក. វត្តមាន

ថ្វីបើ លោក **អៀង សារី** (*មើលក្នុងផ្នែកទី៣.ក*) មានបំណងចង់តាមដានសវនាការដោយផ្ទាល់ពីបន្ទប់សវនាការក្តីក៏ដោយ ក៏គាត់អាចត្រឹមតែបានចូលរួមតាមដានពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការតែប៉ុណ្ណោះពេញមួយសប្ដាហ៍នេះ។ លោក **នួន ជា** បានចូលរួមតាមដានសវនាការដោយផ្ទាល់តែពេលព្រឹក និងត្រូវបានអនុញ្ញាតឲ្យទៅតាមដានពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការនៅពេលរសៀល។ មានតែលោក **ខៀវ សំផន** ទេ ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការរៀងរាល់ថ្ងៃនៃពេលធ្វើសវនាការ។

**ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី៖** សប្ដាហ៍នេះ មានដើមបណ្ដឹងរដ្ឋប្បវេណីប្រមាណជាពី២០ទៅ៣០នាក់ បានចូលរួមតាមដានសវនាការ។ ពួកគាត់ខ្លះបានអង្គុយនៅក្នុងបន្ទប់តុលាការ ខ្លះទៀតអង្គុយតាមដានពីសាលសាធារណជន។

**ការចូលរួមរបស់ភាគី៖** ភាគីទាំងអស់បានបង្ហាញខ្លួនក្នុងអំឡុងពេលដំណើរការសវនាការ លើកលែងតែមេធាវីជាតិការពារក្តីលោក **នួន ជា** គឺលោក **សុន អារុណ** បានអវត្តមានកាលពីរសៀលថ្ងៃសុក្រ។ កាលពីថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះបានទទួលស្គាល់លោកស្រី **អ៊ីស្សាបែល ឌូរ៉ាន** មកពីក្រុមមេធាវីគ្មានព្រំដែនបារាំងជាមេធាវីអន្តរជាតិមួយរូបទៀតតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។

**ការចូលរួមពីសាធារណជនៈ**

| កាលបរិច្ឆេទ | ពេលព្រឹក | ពេលរសៀល |
|---|---|---|
| ថ្ងៃអង្គារ ០៤/១២/១២ | ▪ ៤៣នាក់ ជាប្រជាជនមកពីខេត្តផ្សេងៗ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM)។<br>▪ ៣៧០នាក់ ជាសិស្សមកពីអង្គការសង្គ្រោះក្មេងកំព្រា។<br>▪ ០៩នាក់ ជាអ្នកសង្កេតការណ៍អន្តរជាតិ។ | ▪ ២០០នាក់ ជាប្រជាពលរដ្ឋភាគច្រើនមកពីខេត្តកណ្តាល និងប្រជាពលរដ្ឋផ្សេងទៀតមកពីខេត្តតាកែវ។<br>▪ ០៤នាក់ ជាអ្នកសង្កេតការណ៍អន្តរជាតិ។ |
| ថ្ងៃពុធ ០៥/១២/១២ | ▪ ២៣០នាក់ ជានិស្សិតមកពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តកំពង់ចាម។<br>▪ ០១អង្គ ជាព្រះសង្ឃ។<br>▪ ២២នាក់ ជាអ្នកសង្កេតការណ៍អន្តរជាតិ។ | ▪ ២០០នាក់ ជាប្រជាពលរដ្ឋមកពីខេត្តចម្រុះ។<br>▪ ០២នាក់ ជាអ្នកសង្កេតការណ៍អន្តរជាតិ។ |
| ថ្ងៃព្រហស្បតិ៍ ០៦/១២/១២ | ▪ ៤៣០នាក់ ជាប្រជាពលរដ្ឋមកពីខេត្តព្រៃវែង។<br>▪ ០១អង្គ ជាព្រះសង្ឃ។<br>▪ ៤នាក់ ជាអ្នកសង្កេតការណ៍អន្តរជាតិ។ | ▪ ២៧០នាក់ ជាសិស្សមកពីអង្គការសង្គ្រោះក្មេងកំព្រា។<br>▪ ០៤នាក់ ជាអ្នកសង្កេតការណ៍អន្តរជាតិ។ |
| ថ្ងៃសុក្រ ០៧/១២/១២ | ▪ ៣៧០នាក់ ជាប្រជាពលរដ្ឋមកពីស្រុកសំរោង ខេត្តតាកែវ។<br>▪ ១០នាក់ អ្នកសង្កេតការណ៍អន្តរជាតិ។ | ▪ ១០០នាក់ ជាប្រជាពលរដ្ឋមកពីស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។<br>▪ ០២នាក់ ជាអ្នកសង្កេតការណ៍អន្តរជាតិ។ |

## ខ. ការគ្រប់គ្រងពេលវេលា

តុលាការ បានធ្វើសវនាការពីថ្ងៃអង្គាររហូតដល់ថ្ងៃសុក្រ ហើយដំណើការនីតិវិធីត្រូវបានធ្វើប្រកបដោយភាពជោគជ័យ ក្នុងការស្តាប់សក្ខីកម្មពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប និងសាក្សីមួយរូប។ អង្គជំនុំជម្រះ បានធ្វើការណែនាំដល់សាក្សី **ហ៊ុន ឈុនលី** វិលមកផ្តល់សក្ខីកម្មនៅសប្តាហ៍បន្ទាប់ទៀត ក្រោយពីមេធាវី **កាណាវ៉ាស** បានចង្អុលបង្ហាញថា គាត់ត្រូវការពេលវេលាប្រហែល១ម៉ោង ដើម្បីសួរដេញដោលលើសាក្សីរូបនេះ។

## គ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្ដើម | ការសម្រាក ពេលព្រឹក | អាហារថ្ងៃត្រង់ | ការសម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោង សរុប |
|---|---|---|---|---|---|---|
| ថ្ងៃអង្គារ ០៤/១២/១២ | ៩:០៦ | ៩:៤០-១០:២៦ | ១២:១២-១៣:៣៩ | ១៤:៣៤-១៤:៥៦ | ១៦:០៣ | ៤ម៉ោង និង ២២នាទី |
| ថ្ងៃពុធ ០៥/១២/១២ | ៩:០៥ | ១០:៣២-១០:៥៤ | ១២:១៥-១៣:៣៥ | ១៤:៤៣-១៥:១២ | ១៦:០៥ | ៤ម៉ោង និង ៤៩នាទី |
| ថ្ងៃព្រហស្បតិ៍ ០៦/១២/១២ | ៩:០៣ | ១០:១៨-១០:៣៨ | ១២:០៣-១៣:៣១ | ១៤:៤៣-១៥:០៦ | ១៦:០៣ | ៤ម៉ោង និង ៤៩នាទី |
| ថ្ងៃសុក្រ ០៧/១២/១២ | ៩:០៥ | ១០:៤០-១១:០១ | ១២:០៤-១៣:៣២ | ១៤:៤៥-១៥:០៦ | ១៦:២០ | ៥ម៉ោង និង ០៥នាទី |

ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ ៖ *៤ ម៉ោង និង៤៦*នាទី

ចំនួនម៉ោងសរុបក្នុងសប្ដាហ៍នោះ ៖ *១៩* ម៉ោង និង *០៥* នាទី

*ចំនួនសរុបនៃម៉ោង ថ្ងៃ និង សប្ដាហ៍ ៖* *៥៩២ម៉ោង និង ៣៣នាទី*

***សវនាការរយៈពេល១៣៤ថ្ងៃ អំឡុងពេល ៤១ សប្ដាហ៍***

**Unless specified otherwise,**

- the documents cited in this report pertain to The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan (Case No. 002/19-09-2007-ECCC) before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WCSC WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center,University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Faith Suzzette Delos Reyes, Hava Mirell, Noyel Ry, Kimsan Soy, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach

Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] Trial Chamber. Transcript of Trial Proceedings (6 December 2012). E1/149.1 [hereinafter **6 DECEMBER TRANSCRIPT**]. Lines 16-17. 28.
[2] Trial Chamber. Transcript of Trial Proceedings (4 December 2012).E1/147.1 [hereinafter **4 DECEMBER TRANSCRIPT**]. Lines 17-21. 52.
[3] Ibid, lines 23-25; 1-7. 99-100.
[4] Ibid, lines 23-25; 1. 100-101.
[5] The Civil Party said that her husband was a "military medic" for the Lon Nol regime.
[6] Trial Chamber. Transcript of Trial Proceedings (5 December 2012).E1/148.1 [hereinafter **5 DECEMBER TRANSCRIPT**]. Lines 20-24. 43.
[7] Ibid, lines 15-17. 42.
[8] Ibid, lines 8-10. 48.
[9] Ibid, lines 9-12. 54.
[10] Ibid, line 6. 51.
[11] Ibid, line 20. 52.
[12] The Civil Party said: "That old man, who worked for the commerce for the location, asked that I could be kept there for a while before being executed. And later on he came back with another militia -- I mean, the old man - and said that the matter was already resolved and that I should be left with that old man. So, luckily, I was saved." Ibid, lines 4-8. 53.
[13] Ibid, lines 14-29. 71.
[14] Ibid, lines 4-7. 75.
[15] Ibid, lines 20-21. 84.
[16] Ibid, lines 3-8. 107.
[17] Ibid, line 6. 107.
[18] 6 DECEMBER TRANSCRIPT. Line 18. 12.
[19] Ibid, lines 13-14. 28.
[20] Ibid, lines 16-17. 28.
[21] Witness Hun Chhunly was examined in the following order: national Prosecutor VengHuot; international Prosecutor TarikAbdulhak; Civil Party Lawyer VenPov; Civil Party Lawyer Elisabeth Simonneau-Fort; counsels for NuonChea, Son Arun and Jasper Pauw; counsels for KhieuSamphan, Anta Guissé and Kong Sam Onn.
[22] The Witness said he started writing his book in 2004, but the memories form the regime made it difficult for him to sleep, so he had to stop writing for a while.
[23] Trial Chamber. Transcript of Trial Proceedings (7 December 2012).E1/150.1 [hereinafter **7 DECEMBER TRANSCRIPT**]. Lines 16-20. 42.
[24] Ibid, lines 6-8. 16.
[25] 6 DECEMBER TRANSCRIPT. Lines 19-20. 70.
[26] The Witness stated that he did not know the ultimate fate of Khek Pen, saying that "it was a period of screening or purging," so he did not know what happened to him.
[27] 6 DECEMBER TRANSCRIPT. Lines 1-4. 84.
[28] Ibid, line 11. 74.
[29] Ibid, lines 10-19. 75.
[30] Ibid, lines 16-18. 108.
[31] Ibid, lines 20-23. 83.
[32] Ibid, lines 12-14. 102.
[33] Ibid, lines 7-8. 95.
[34] Ibid, lines 1-5. 69.
[35] 7 DECEMBER TRANSCRIPT.Lines 6-7. 87.
[36] *See* The Defence for IengSary. "IengSary's Withdrawal of Waivers of Right to be Present" (3 December 2012). E237/2.
[37] According to the Internal Rules, the Trial Chamber can order an Accused to participate in the proceedings through appropriate audio-visual means: "Where, due to health reasons or other serious concerns, the Accused cannot attend in person before the Chamber but is otherwise physically and mentally fit to participate, the Chamber may either continue the proceedings in the Accused's absence with his or her consent or, where the Accused's absence reaches a level that causes substantial delay and, where the interests of justice so require, order that the Accused's participation before the Chamber shall be by appropriate audio-visual means." (Internal Rules (Rev. 8). Rule 85 (1). (3 August 2011).
[38] According to Karnavas, when he asked the holding cell doctor whether IengSary was capable of following the proceedings all day long, the holding cell doctor simply laughed in response.
[39] 4 DECEMBER TRANSCRIPT.Lines 1-5. 4.

[40] Karnavas claimed that he had made a similar request in the past, and in response, the Trial Chamber held a "secret meeting," which included the Trial Chamber, the Prosecution, the Defence Support Section, and the administration (but not the Defence) to discuss something "completely different" related to the Court's facilities.

[41] 4 DECEMBER TRANSCRIPT.Lines 11-14. 5.

[42] *See e.g.*, The Defence for IengSary. "IengSary's Submission Of His Defence Team's Daily Observations From The Holding Cell Concerning Mr. IengSary's Condition For 6 December 2012" (7 December 2012), E248/1.

[43] *See* The Office of the Co-Prosecutors. "Co-Prosecutors' Response to "IengSary's Supplemental Request For A Qualified Expert To Make Daily Medical Examinations Related To Mr. IengSary's Capacity To Assist In His Own Defence Or, In The Alternative, Request For The Trial Chamber To Order The ECCC Doctors To Make Specific Observations Relevant to Mr. IengSary's Capacity To Assist In His Own Defence" (14 December 2012), E255/1 [hereinafter **14 DECEMBER 2012 SUBMISSION** ].

[44] In the conclusion of its submission, it suggested that the following categories of information be included in the Medical Unit's daily reports to the Trial Chamber:

(a) A summary of IengSary's overall physical and mental condition on the day;
(b) Observations as to whether IengSary is generally able to follow the proceedings (understand what is being said, and by whom) when he is awake;
(c) Observations as to whether IengSary is able to communicate with those around him (express his requests, and understand the responses of those he is communicating with); and
(d) A recommendation whether IengSary would be accommodated better in the holding cell or in the courtroom, in light of IengSary's health needs and comfort.

[45] For more information on Fitness Standards, *See*CASE 002 KRT TRIAL MONITOR*.* Special Report: IengThirith's Fitness to Stand Trial (November 2012).

[46] *Deputy General Prosecutor for Serious Crimes v. JosepNahak*, Findings and Order on Defendant Nahak's Competence to Stand Trial, 1 March 2005, para. 54. See also *Prosecutor v. Vladimir Kovacevic*. Case No. IT-01-42/2-I, Public Version of the Decision on Accused's Fitness to Enter a Plea and Stand Trial, 12 April 2006, para 5.

[47] Ibid, para.23, *in* 14 DECEMBER 2012 SUBMISSION.

[48] *See* CASE 002 KRT TRIAL MONITOR. Issue No. 44, Hearing on Evidence Week 39 (22-23 November 2012). 11-12.

[49] 4 DECEMBER TRANSCRIPT.Lines 20-25; 4-7. 30-31.

[50] Ibid, lines 1-2. 32.

[51] *See* The Defence for KhieuSamphan. "Application for Reconsideration of the Decision Not to Recall Civil Party TCCP-187, and for Review of the Procedure for Hearing Civil Parties" (7 December 2012), E250.

[52] 4 DECEMBER TRANSCRIPT. Lines 7-13. 33.

[53] Ibid, lines 1-6. 34.

[54] 6 DECEMBER TRANSCRIPT.Lines 12-25; 1-6. 52-53.

[55] Ibid, lines 23-24. 55.

[56] Ibid, lines 23-24. 56.

[57] Ibid, lines 1-2. 57.